សហប្រជាជាតិ

# A

ការបកប្រែ
ក្រៅផ្លូវការ

**មហាសន្និបាត**

ចែកចាយទូទៅ

A/HRC/7/56
ថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ២០០៨

ច្បាប់ដើម : ភាសាអង់គ្លេស

**ក្រុមប្រឹក្សាសិទ្ធិមនុស្ស**
សម័យប្រជុំលើកទី៧
របៀបវារៈ ចំណុចទី២

## របាយការណ៍ប្រចាំឆ្នាំរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស និងរបាយការណ៍របស់ការិយាល័យឧត្តមស្នងការ និងអគ្គលេខាធិការអង្គការសហប្រជាជាតិ

## តួនាទីនិងសមិទ្ធិផលសំរេចបានរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងការជួយដល់រដ្ឋាភិបាលនិងប្រជាជនកម្ពុជាដើម្បីលើកស្ទួយនិងការការពារសិទ្ធិមនុស្ស

### របាយការណ៍របស់លោកអគ្គលេខាធិការ អ.ស.ប

## សេចក្តីសង្ខេប

របាយការណ៍នេះ ត្រូវបានដាក់ជូនស្របតាមសេចក្តីសំរេចលេខ ២/១០២ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្សដែលបានស្នើឱ្យលោកអគ្គលេខាធិការ និងឧត្តមស្នងការអង្គការសហប្រជាជាតិបន្តការងាររបស់ខ្លួននៅកម្ពុជាតទៅទៀត ស្របតាមសេចក្តីសំរេចទាំងឡាយកន្លងមក ដែលបានអនុម័តដោយគណៈកម្មការសិទ្ធិមនុស្ស និង ពិនិត្យឡើងវិញលើរបាយការណ៍និងការសិក្សានានាដែលពាក់ព័ន្ធ។

# មាតិកា

*កថាខ័ណ្ឌ ទំព័រ*

សេចក្តីផ្តើម ........................................................................................................ ១-៣......៤

I. សកម្មភាពរបស់ការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សក្នុងការ
ជួយដល់រដ្ឋាភិបាល និងប្រជាជនកម្ពុជាដើម្បីលើកស្ទួយនិងការពារសិទ្ធិមនុស្សនៅកម្ពុជា...... ៤-៥៩...... ៥

ក. វិធីសាស្ត្របន្តរបស់ការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា៤-៦ ..... ៥

ខ. សិទ្ធិនិងសេរីភាពជាមូលដ្ឋាន និងសង្គមស៊ីវិល .................................................. ៧-២១......៧

គ. នីតិរដ្ឋ និងវិស័យយុត្តិធម៌.......................................................................២២-២៨ ..១៣

ឃ. និទ្ទណ្ឌភាព..........................................................................................២៩-៣៣ .. ១៥

ង. ដីធ្លី និងការចិញ្ចឹមជីវិត.............................................................................. ៣៤-៤៥... ១៧

ច. ការប្រកាន់ខ្ជាប់សន្ធិសញ្ញានានាស្តីពីសិទ្ធិមនុស្សអន្តរជាតិ....................................៤៦-៤៨... ២២

ឆ. កិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិមួយ................................៤៩-៥០...២៣

ជ. កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលជាមួយក្រុមអង្គការសហប្រជាជាតិ
ប្រចាំប្រទេស.........................................................................................៥១-៥៣... ២៤

ឈ. កម្មវិធីអប់រំ បណ្តុះបណ្តាល និងព័ត៌មានសាធារណៈ..........................................៥៤-៥៨... ២៥

II. ការជួយឧបត្ថម្ភដល់តំណាងពិសេសរបស់លោកអគ្គលេខាធិការ អ.ស.ប ទទួល
បន្ទុកសិទ្ធិមនុស្សនៅកម្ពុជា........................................................................................ ៥៩ .. ២៦

III. កិច្ចការបុគ្គលិក និងរដ្ឋបាលរបស់ការិយាល័យឧត្តមស្នងការ អ.ស.ប
ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា.......................................................................៦០-៦៣ .. ២៧

# សេចក្តីផ្តើម

១. ក្នុងការបំពេញការងាររបស់ខ្លួន ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHRឬការិយាល័យ) បានបន្តអនុវត្តតាមសេចក្តីសំរេចលេខ២០០៥/៧៧ របស់គណៈកម្មការសិទ្ធិមនុស្ស ដែលបានអញ្ជើញលោកអគ្គលេខាធិការ ទីភ្នាក់ងារនានានៃប្រព័ន្ធសហប្រជាជាតិដែលមានវត្តមាននៅកម្ពុជា ព្រមទាំងសហគមន៍អន្តរជាតិ រួមទាំងអង្គការក្រៅរដ្ឋាភិបាលផងដែរ ឱ្យបន្តធ្វើការជាមួយរដ្ឋាភិបាលកម្ពុជា ក្នុងការធានាដល់ការការពារនិងលើកស្ទួយសិទ្ធិមនុស្សរបស់ប្រជាជនគ្រប់រូបនៅកម្ពុជា។

២. នៅក្នុងសេចក្តីសំរេចលេខ២០០៥/៧៧ របស់គណៈកម្មការនេះ បានស្នើឱ្យរដ្ឋាភិបាលកម្ពុជា បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនថែមទៀត ដើម្បីពង្រឹងនីតិរដ្ឋ ដោយរួមទាំងតាមរយៈការអនុម័តនិងការអនុវត្តន៏ច្បាប់និងក្រមសំខាន់ៗ សំរាប់ការបង្កើតសង្គមប្រជាធិបតេយ្យមួយ ដើម្បីដោះស្រាយបញ្ហានិទ្ទណ្ឌភាពជាបញ្ហាអាទិភាព និងបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការស៊ើបអង្កេត និងផ្តន្ទាទោសជនទាំងឡាយដែលបានប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ រួមទាំងការរំលោភសិទ្ធិមនុស្ស ដើម្បីពង្រឹងកិច្ចខិតខំប្រឹងប្រែងក្នុងការធានាឯករាជ្យភាព ភាពមិនលំអៀង និងប្រសិទ្ធិភាពនៃប្រព័ន្ធយុត្តិធម៌ និងចាត់វិធានការផ្សេងៗ ដើម្បីបំពេញកាតព្វកិច្ចក្រោមលិខិតុបករណ៏ សិទ្ធិមនុស្សអន្តរជាតិ ប្រយុទ្ធប្រឆាំងនឹងបញ្ហាធំៗ ដូចជាការជួញដូរមនុស្ស អំពើហឹង្សាខាងផ្លូវភេទ អំពើហឹង្សាក្នុងគ្រួសារ និងការធ្វើអាជីវកម្មផ្លូវភេទលើស្រ្តីនិងកុមារ ពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការដោះស្រាយបញ្ហាកម្មសិទ្ធិដីធ្លីដោយសមធម៌ និងឆាប់រហ័សក្នុងភាពត្រឹមត្រូវនិងដោយចំហរ ស្របទៅតាមច្បាប់ភូមិបាល ហើយបន្តបង្កើតបរិយាកាសងាយស្រួល ក្នុងការធ្វើសកម្មភាពនយោបាយស្របច្បាប់ ក៏ដូចជាគាំទ្រដល់តួនាទីរបស់អង្គការក្រៅរដ្ឋាភិបាលនានា ដើម្បីពង្រឹងការអភិវឌ្ឍន៏លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។

៣. អនុស្សារណៈស្តីពីការយោគយល់គ្នារយៈពេលពីរឆ្នាំ (MOU) រវាងរាជរដ្ឋាភិបាលកម្ពុជា និងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស សំរាប់ការអនុវត្តន៏កម្មវិធីសហប្រតិបត្តិការបច្ចេកទេសក្នុងវិស័យសិទ្ធិមនុស្សបានចប់ក្នុងខែមករា ឆ្នាំ២០០៧។ ក្រោយពីមានការពិភាក្សាគ្នាយ៉ាងយូរជាមួយរដ្ឋាភិបាលរួចមក ឧត្តមស្នងការបានចុះហត្ថលេខាលើអនុស្សារណៈស្តីពីការយោគយល់គ្នា(MOU) ថ្មីនៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០០៧ សំរាប់រយៈពេល១៨ ខែបន្តទៀត។ រយៈពេលបន្តនេះមានការយល់ព្រមជាពិសេសនិងដោយផ្អែកលើការយោគយល់គ្នាថា ការចរចាមានគោលដៅចុះកិច្ចព្រមព្រៀងតាមបទដ្ឋានមួយសំរាប់ប្រតិបត្តិការនៅថ្ងៃខាងមុខរបស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស OHCHR នៅកម្ពុជា ដែលនឹងត្រូវបន្តអនុវត្តនៅឆ្នាំក្រោយ។ មានការព្រមព្រៀងផងដែរថា នឹងបន្តកិច្ចខិតខំប្រឹងប្រែងរួមគ្នា ដើម្បីធ្វើឱ្យប្រសើរឡើង

នូវការយោគយល់គ្នា និងធ្វើការពិភាក្សានិងសហប្រតិបត្តិការតទៅទៀត រវាងការិយាល័យនេះនិងរដ្ឋាភិបាល ។ នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ ការិយាល័យបានសហការជាមួយស្ថាប័ននានារបស់រដ្ឋាភិបាល ដែលទទួលខុសត្រូវក្នុងវិស័យសិទ្ធិមនុស្ស អង្គការក្រៅរដ្ឋាភិបាលនិងអង្គការនានា ដែលធ្វើការដោយផ្ទាល់នៅតាមសហគមន៍ ព្រមទាំងក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេស និងទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍ទ្វេរភាគីនិងពហុភាគី ។

## I. សកម្មភាពការងាររបស់ការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងការជួយដល់រដ្ឋាភិបាលនិងប្រជាជនកម្ពុជាក្នុងការលើកស្ទួយនិងការពារសិទ្ធិមនុស្សនៅកម្ពុជា

### ក. វិធីសាស្ត្របន្តរបស់ការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា

៤. កម្មវិធីរបស់ការិយាល័យនេះត្រូវបានរៀបចំឡើងផ្តោតលើវិស័យសំខាន់ៗចំនួនបីដែលទាក់ទងគ្នា (ក) សិទ្ធិនិងសេរីភាពជាមូលដ្ឋាន ព្រមទាំងសង្គមស៊ីវិល (ខ) នីតិរដ្ឋ និង (គ) ដីធ្លីនិងការចិញ្ចឹមជីវិត ។ ក្នុងវិស័យទាំងបីនេះ ការិយាល័យឃ្លាំមើលការអភិវឌ្ឍន៍វិស័យពាក់ព័ន្ធនានា ធ្វើការវិភាគច្បាប់ពាក់ព័ន្ធនឹងការអនុវត្តន៍សិទ្ធិទាំងនេះ ផ្តល់ជំនួយផ្នែកបច្ចេកទេសដល់ស្ថាប័ននានានៃរដ្ឋាភិបាលក្នុងការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីធានាថា ច្បាប់និងការអនុវត្តន៍ច្បាប់ស្របតាមរដ្ឋធម្មនុញ្ញនិងកាតព្វកិច្ចសន្ធិសញ្ញារបស់កម្ពុជា រៀបចំបទអន្តរាគមន៍ផ្សេងៗ តាមការចាំបាច់ ដើម្បីទាញចំណាប់អារម្មណ៍របស់អាជ្ញាធរទាំងនេះចំពោះការរំលោភ ឬបញ្ហាដែលជាកង្វល់ធ្ងន់ធ្ងរ ធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គការសង្គមស៊ីវិលទាំងឡាយដែលពាក់ព័ន្ធនឹងវិស័យច្បាប់ សេដ្ឋកិច្ច និងសង្គមកិច្ច និង ជួយការពារសមត្ថភាពរបស់សង្គមស៊ីវិលក្នុងការប្រត្តិបត្តិការការងារ ។ ការិយាល័យធ្វើការជិតស្និទ្ធផងដែរជាមួយអង្គការដទៃទៀត ក្នុងប្រព័ន្ធសហប្រជាជាតិ និងជាមួយតួអង្គអន្តរជាតិនិងអ្នកផ្តល់ជំនួយបរទេសឯទៀត ។ ផ្នែកនីមួយៗយកចិត្តទុកដាក់បំផុតក្នុងការរៀបចំចងក្រងឯកសារ និងធ្វើការវិភាគយ៉ាងហ្មត់ចត់លើបញ្ហាទាំងឡាយ ដែលខ្លួនទទួលខុសត្រូវ ដើម្បីពិនិត្យផ្ទៀងផ្ទាត់ព័ត៌មាន និងកំណត់អង្គហេតុតាមលក្ខណៈសត្យានុម័ត ដើម្បីរៀបចំទិន្នន័យ មួយដែលជឿជាក់បានសំរាប់ប្រើប្រាស់ និងចាត់ការដោយការិយាល័យក្នុងកម្មវិធីកិច្ចសហប្រតិបត្តិការ ជាមួយរដ្ឋាភិបាលសង្គមស៊ីវិល និងតួអង្គអន្តរជាតិដែលមានចំណាប់អារម្មណ៍ ។

៥. កិច្ចការឃ្លាំមើលនិងការពាររបស់ការិយាល័យឧត្តមស្នងការ គឺជាផ្នែកដែលជាប់បតិដ្ឋាប័ននៃអាណត្តិសហប្រតិបត្តិការបច្ចេកទេសរបស់ខ្លួន ។ អាណត្តិនេះអនុញ្ញាតឱ្យការិយាល័យធានាផ្តល់ជំនួយផ្នែកបច្ចេកទេសពាក់ព័ន្ធនឹងសេចក្តីត្រូវការ ដែលកំណត់ដោយដៃគូរដ្ឋាភិបាលផង និងការវិភាគដោយការិយាល័យអំពីបញ្ហាសិទ្ធិមនុស្ស និង

បញ្ហាជាអាទិភាពដទៃទៀតនៅក្នុងប្រទេសផង ។ ការិយាល័យធ្វើការវិភាគអំពីស្ថានការណ៍និងករណីផ្សេងៗ ដែលជាកង្វល់ធ្ងន់ធ្ងរក្នុងលក្ខណៈត្រឹមត្រូវនិងសត្យានុម័ត ធ្វើការពាំនាំព័ត៌មានទាំងនេះប្រាប់ទៅអាជ្ញាធរពាក់ព័ន្ធ ជំរុញលើកទឹកចិត្តឱ្យអាជ្ញាធរទាំងឡាយធ្វើការដោះស្រាយស្ថានការណ៍និងករណីទាំងនេះ និងចាត់វិធាការនានា ដើម្បីទប់ស្កាត់និងកែតម្រូវ ។ កិច្ចសហប្រតិបត្តិការនេះត្រូវបានធ្វើឡើងតាមរយៈការពិភាក្សាដោយផ្ទាល់ជាមួយរដ្ឋាភិបាល តាមរយៈការផ្តល់ជំនួយផ្នែកបច្ចេកទេស និងជំនួយផ្សេងៗទៀត ដើម្បីពិនិត្យទៅលើបញ្ហានានានិងរិះរកវិធីធ្វើការជាមួយគ្នាដើម្បីដោះស្រាយបញ្ហាទាំងនោះ ។ ការិយាល័យកំពុងដំណើរការរៀបចំបង្កើតឡើងវិញនូវកម្មវិធីសហប្រតិបត្តិការផ្នែកបច្ចេកទេស ដោយផ្អែកលើការពិគ្រោះយោបល់ ការវិភាគរួម ការកំណត់រួមអំពីបញ្ហាអាទិភាព និងការបង្កើតទម្រង់ត្រឹមត្រូវនៃការគាំទ្រក្នុងស្មារតីនៃភាពជាដៃគូ ។ ការពិភាក្សារវាងការិយាល័យនិងរដ្ឋាភិបាលគឺជាកត្តាសំខាន់សំរាប់បង្កើតកិច្ចសហប្រតិបត្តិការដែលផ្តល់ផលប្រយោជន៍ទាំងសងខាងផ្អែកលើការទុកចិត្តគ្នាទៅវិញទៅមក ។ ការិយាល័យមិនមានបំណងធ្វើការពិភាក្សាអំពីកិច្ចការទាំងឡាយដែលពាក់ព័ន្ធនឹងរដ្ឋាភិបាល តាមរយៈប្រព័ន្ធសារព័ត៌មានឡើយ ។ ផ្ទុយទៅវិញ ការិយាល័យមានបំណងពិភាក្សាដោយផ្ទាល់និងសហការ ដែលជាមធ្យោបាយសំខាន់ដើម្បីលើកឡើង និងដោះស្រាយបញ្ហាដែលជាកង្វល់ក្នុងស្មារតីគោរព យោគយល់គ្នា និងក្នុងភាពជាដៃគូ ។

៦. ចាប់តាំងពីឆ្នាំ១៩៩៣មក ការិយាល័យបានព្យាយាមគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល សង្គមស៊ីវិល និងសហគមន៍អន្តរជាតិ ដើម្បីកសាងនីតិរដ្ឋឡើងវិញនៅកម្ពុជា ស្របតាមរដ្ឋធម្មនុញ្ញនិងកាតព្វកិច្ចសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ។ គោលដៅទូទៅនេះ ត្រូវបានអនុវត្តនៅក្នុងវិស័យពាក់ព័ន្ធចំនួនបួនរួមមាន : ការគាំទ្រដល់កិច្ចដំណើរការព្រាងច្បាប់ដើម្បីធានាថា ច្បាប់ទាំងឡាយដែលបានអនុម័តមានបញ្ញត្តិដែលធានាការពារសិទ្ធិរឹងមាំបំផុត, ការគាំទ្រដល់ការកសាងឡើងវិញនូវស្ថាប័ននានា ដែលសំខាន់ចាំបាច់សំរាប់នីតិរដ្ឋ ( តុលាការ វិជ្ជាជីវៈច្បាប់ នគរបាល), ការឃ្លាំមើលការអនុវត្តន៍ដោយអាជ្ញាធរសាធារណៈ នូវបញ្ញត្តិដែលធានាដោយរដ្ឋធម្មនុញ្ញ និងសិទ្ធិស្របច្បាប់, និងការគាំទ្រដល់ការបង្កើត និងការការពារសង្គមស៊ីវិល ។ ការិយាល័យបានបន្តលើកស្ទួយ និងបានរួមចំណែកក្នុងការការពារសិទ្ធិរស់រានមានជីវិត សន្តិសុខនិងបូរណភាពផ្ទាល់ខ្លួន និងការអនុវត្តន៍សេរីភាពក្នុងការសំដែងមតិ សេរីភាពក្នុងការបង្កើតសមាគម និងសេរីភាពក្នុងការប្រជុំ ។ ការិយាល័យបានតាមដានយ៉ាងជិតដល់ចំពោះការងាររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ECCC) ក្នុងគោលបំណងបញ្ចូលទំលាប់អនុវត្តន៍ល្អទៅក្នុងប្រព័ន្ធតុលាការទូទៅ ។ ការិយាល័យបានឃ្លាំមើលនិងវិភាគលើការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិ និងផលប៉ះពាល់របស់វាទៅលើសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ជាពិសេស សិទ្ធិលើទ្រព្យសម្បត្តិ ដីធ្លី សិទ្ធិមានផ្ទះសម្បែងសមរម្យ និងសិទ្ធិជនជាតិដើមភាគតិចលើដីធ្លី និងធនធានធម្មជាតិនានា ។ ការិយាល័យបានព្យាយាមផងដែរ ដើម្បីឃ្លាំមើលនិន្នាការនិងបានទទួលដោះស្រាយករណី

ទាំងឡាយដែលទាក់ទងការរិតត្បិត ឬការរំលោភសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយរបស់បុគ្គលនិងក្រុម ដែលព្យាយាម លើកកំពស់សិទ្ធិលើដីធ្លីនិងផ្ទះសម្បែង ជាពិសេស សេរីភាពក្នុងការប្រជុំ និងសេរីភាពក្នុងការដើរហើរ និងសិទ្ធិទទួល បានការដោះស្រាយប្រកបដោយប្រសិទ្ធិភាព និងសិទ្ធិទទួលបានការការពារស្មើភាពគ្នាចំពោះមុខច្បាប់ ។

## ៩. សិទ្ធិនិងសេរីភាពជាមូលដ្ឋាននិងសង្គមស៊ីវិល

៧. ការិយាល័យបានយកចិត្តទុកដាក់ជាពិសេសចំពោះករណីផ្សេងៗ ដែលអង្គការក្រៅរដ្ឋាភិបាលនិងសកម្មជន នានា ដែលទទួលរងការវាយប្រហារ ពាក់ព័ន្ធនឹងសកម្មភាពស្របច្បាប់របស់ពួកគេ ក្នុងការលើកស្ទួយនិងការការពារ សិទ្ធិមនុស្ស ក៏ដូចជាករណីទាំងឡាយមានលក្ខណៈជាលំនាំទូទៅ ដែលមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើការប្រើប្រាស់ សិទ្ធិមនុស្សសំខាន់ៗបំផុត ។ ចំពោះបញ្ហានេះ ការិយាល័យបានពាំនាំនូវកង្វល់របស់ខ្លួនប្រាប់អាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ ខេត្តអំពីការរិតត្បិតលើសេរីភាពក្នុងការដើរហើរ សេរីភាពក្នុងការសំដែងមតិ សេរីភាពក្នុងការបង្កើតសមាគម និងសេរី ភាពក្នុងការប្រជុំ ការចាប់ខ្លួនដោយខុសច្បាប់ ការបាត់ខ្លួន និងការរំលោភធ្ងន់ធ្ងរដទៃទៀតលើបញ្ញត្តិដែលធានាខាងនីតិ វិធីច្បាប់ ជំលោះដីធ្លី និងលទ្ធកម្មលើដីធ្លីដោយខុសច្បាប់ ការបណ្តេញចេញដោយប្រើកំលាំងនិងដោយហឹង្សា ការប្រើប្រាស់កំលាំងហួសហេតុ និងស្ថានភាពពន្ធនាគារ ។

៨. នៅក្នុងរយៈពេលមួយឆ្នាំ តាមរយៈការផ្តល់សច្ចាប័នលើពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងទារុណកម្ម និង ការប្រព្រឹត្តមកលើខ្លួនឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប កម្ពុជាបានអះអាងជាថ្មី នូវការ ប្តេជ្ញាចិត្តរបស់ខ្លួន ក្នុងការបំបាត់ការធ្វើទារុណកម្មនិងការប្រព្រឹត្តឃោរឃៅ អមនុស្សធម៌ ការិយាល័យបានចងក្រង ឯកសារអំពីករណីជាច្រើន ដែលក្នុងនោះមន្ត្រីរដ្ឋាភិបាលមួយចំនួនជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តឃោរឃៅ អមនុស្សធម៌ ឬការធ្វើទារុណកម្ម ។ ក្នុងករណីមួយ បុរសម្នាក់ត្រូវបានគេធ្វើទារុណកម្មក្នុងមន្ទីរឃុំឃាំងរបស់កងរាជអាវុធហត្ថ នៅ ក្នុងឃុំទីរឹង ខេត្តកំពង់ធំ ។ ដោយសារតែគាត់រងរបួសធ្ងន់ធ្ងរខ្លាំងពេក គាត់បានបាត់បង់ជីវិតនៅថ្ងៃទី១ ខែមករា ឆ្នាំ ២០០៧ គឺរយៈពេលមួយថ្ងៃបន្ទាប់ពីគេដោះលែងគាត់ឱ្យមានសេរីភាពវិញ ។ បន្ទាប់ពីមានការស៊ើបអង្កេតរបស់ នគរបាលនិងការធ្វើកោសល្យវិច្ច័យ បានបញ្ជាក់ថា បុរសនោះបានស្លាប់ដោយសារការធ្វើទារុណកម្ម ហើយនគរបាល បានប្តឹងទៅតុលាការខេត្ត ។ មានការសង្ស័យថា មន្ត្រីកងរាជអាវុធហត្ថមួយចំនួនបានបង់ប្រាក់ឱ្យប្រពន្ធអ្នកស្លាប់ ក្នុងការព្យាយាមដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ។ ការិយាល័យក៏បានស៊ើបអង្កេតករណីនៃការចាប់ខ្លួនមនុស្ស ខុសច្បាប់និងការធ្វើទារុណកម្មទៅលើបុគ្គលិកយោធាម្នាក់ដោយកងឯកភាពយោធាមួយ ពាក់ព័ន្ធនឹងការធ្វើចំការមួយ នៅក្រុងប៉ៃលិន និងការបាត់ខ្លួនរបស់គាត់នៅពេលក្រោយមក ។ មន្ត្រីនគរបាលនិងយោធាដែលបានស៊ើបអង្កេតករណី

នេះ បានធ្វើការសន្និដ្ឋានថាបុរសនោះត្រូវគេសំលាប់ ប៉ុន្តែគេមិនអាចរកឃើញសាកសពគាត់ឡើយ ។ មានការផ្តល់សំណងជាប្រាក់ដល់គ្រួសារនេះ ប៉ុន្តែមិនមានការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ឬការដាក់វិន័យណាមួយទៅលើជនល្មើសឡើយ ។ ក្នុងករណីមួយទៀត ការិយាល័យបានស៊ើបអង្កេតករណីដែលគេអះអាងថាមានការវាយដំពិរុទ្ធជនបីនាក់ដើម្បីជាទណ្ឌកម្មដែលជនទាំងនោះបានព្យាយាមរត់គេចខ្លួនចេញពីពន្ធនាគារខេត្តកណ្តាល នៅថ្ងៃទី ២២-២៣ ខែកក្កដា ឆ្នាំ២០០៧ ។ ហាក់ដូចជាមិនមានការចាត់វិធានការខាងវិន័យដល់មន្ត្រីពន្ធនាគារពាក់ព័ន្ធឡើយ ។ នៅពាក់កណ្តាលខែធ្នូ អាជ្ញាធរពន្ធនាគារបានអនុញ្ញាតឱ្យបុគ្គលិកការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ជួបនិងសម្ភាសន៏ដោយផ្ទាល់និងជាសម្ងាត់ជាមួយពិរុទ្ធជនទាំងបីរូបនោះ និងធ្វើកំណត់ហេតុពីលទ្ធផលដោយភ្ជាប់ជាមួយនូវអនុសាសន៏នានា ស្តីពីវិធានការទប់ស្កាត់និងវិធានការកែតម្រូវដើម្បីដាក់ជូនអាជ្ញាធរពន្ធនាគារ ។ ការិយាល័យបានធ្វើអន្តរាគមន៏ជាមួយអាជ្ញាធរលើករណីជាច្រើនទៀត ទាក់ទងនិងស្ថានភាពព័ន្ធនាគារ ដោយរួមទាំងការប្រើខ្នោះជើង និងការរិតត្បិតសិទ្ធិរបស់គ្រួសារក្នុងការចូលសួរសុខទុក្ខអ្នកទោសមួយចំនួនដែលពាក់ព័ន្ធនឹងរឿងនយោបាយដែលវេទយិតខ្លាំង ។ អាជ្ញាធរពន្ធនាគារបានឆ្លើយតបចំពោះបទអន្តរាគមន៏ភាគច្រើន និងមានការសហការគួរជាទីគាប់ចិត្ត ។

៩.	នៅចុងឆ្នាំ២០០៧ ការិយាល័យបានចាប់ផ្តើមធ្វើការពិគ្រោះយោបល់ជាមួយអគ្គនាយកដ្ឋានព័ន្ធនាគារ និងក្រសួងមហាផ្ទៃ ដើម្បីរិះរកច្រកសំរាប់បង្កើតកិច្ចសហប្រតិបត្តិការនៅក្នុងវិស័យកំណែទម្រង់ពន្ធនាគារ ។ វិស័យបួនដែលអាចគាំទ្រដោយការិយាល័យត្រូវបានកំណត់រួមគ្នា ក្នុងនោះរួមមានការគាំទ្រ ( ការប្រឹក្សាយោបល់ផ្នែកច្បាប់) ក្នុងកិច្ចដំណើរការព្រាងច្បាប់ដោយក្រសួងមហាផ្ទៃ ទាក់ទងនឹងច្បាប់ស្តីពីការរៀបចំប្រព័ន្ធពន្ធនាគារ ការបណ្តុះបណ្តាលវិជ្ជាជីវៈដល់មន្ត្រីពន្ធនាគារ ការវាយតំលៃអំពីស្ថានភាពពន្ធនាគារនិងការប្រព្រឹត្តទៅលើពិរុទ្ធជន និងការគាំទ្រផ្នែកសម្ភារៈ ដើម្បីបំពាក់ឱ្យពន្ធនាគារនូវឧបករណ៏ផ្គត់ផ្គង់ទឹកស្អាតនិងសេវាអានាម័យគ្រប់គ្រាន់ ។ ក្រសួងមហាផ្ទៃក៏បានយល់ព្រមជាគោលការណ៏ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការជាមួយការិយាល័យ ក្នុងវិស័យព្រាងច្បាប់ បញ្ហាដីធ្លីនិងសង្គមស៊ីវិល ។

១០.	នៅក្នុងខែតុលាឆ្នាំ២០០៧ ការិយាល័យបានសរសេរលិខិតមួយច្បាប់ទៅក្រសួងមហាផ្ទៃដើម្បីស្នើឱ្យមានការពន្យល់អំពីករណីនៃការស្លាប់របស់លោក អ៊ុំ ឆាយ នៅកន្លែងឃុំឃាំង ដែលលោកជាពាណិជ្ជករដ៏ល្បីឈ្មោះម្នាក់នៅខេត្តបន្ទាយមានជ័យ ដែលត្រូវបានចាប់ខ្លួនពីបទសង្ស័យថាជាប់ពាក់ព័ន្ធនឹងការផលិត និងការជួញដូរថ្នាំញៀនខុសច្បាប់ ។ មិនមានការស៊ើបអង្កេតឯករាជ្យណាមួយទៅលើករណីនេះទេ ។ ក្នុងលិខិតឆ្លើយតបអាជ្ញាធរបានបញ្ជាក់ថា ការស្លាប់នេះ បណ្តាលមកពីការធ្វើអត្តឃាត ប៉ុន្តែមិនអាចធ្វើការពន្យល់បានគ្រប់គ្រាន់ ថាតើលោកអ៊ុំ ឆាយ អាចរត់គេចខ្លួន ហើយលោតពីយ៉រជាន់ទីមួយដោយរបៀបណាឡើយ ខណៈពេលគាត់កំពុងជាប់ឃុំ ក្រោយពីគាត់បាន

រាយការណ៍ថាមានគេប៉ុនប៉ងសំលាប់គាត់នោះ ។ ដូចគ្នានេះដែរ នគរបាលបដិសេធមិនផ្តល់កំណត់ហេតុជាផ្លូវការ អំពីលទ្ធផលនៃការស៊ើបអង្កេតនេះឡើយ ដោយរួមទាំងលិខិតបញ្ជាក់ពីការធ្វើកោសល្យវិច្ច័យសាកសពផងដែរ ។

១១. បន្ទាប់ពីមានការស្វាគមន៍ចំពោះការកែប្រែបទបរិហាកេរ្តិ៍ក្នុងច្បាប់នៅឆ្នាំ២០០៦ ( ការដកទោសគុកពីបញ្ញត្តិនៃបទបរិហាកេរ្តិ៍) មានការថយចុះយ៉ាងច្បាស់ ក្នុងការចោទប្រកាន់ពីបទបរិហាកេរ្តិ៍ ប៉ុន្តែបទល្មើសនេះបានប្តូរមកជាបទព្រហ្មទណ្ឌមួយបែបទៀត គឺបទផ្សាយព័ត៌មានមិនពិត ដែលនៅតែមានទោសគុកជាដដែល ។ នៅថ្ងៃទី១៥ ខែ កុម្ភៈ ឆ្នាំ២០០៧ ការិយាល័យបានទៅសង្កេតមើលសវនាការកាត់ក្តីខ្មែរក្រោមបីនាក់ នៅតុលាការក្រុងភ្នំពេញពីបទផ្សាយព័ត៌មានមិនពិត ។ អ្នកទាំងនោះត្រូវបានគេចោទប្រកាន់ថាបានធ្វើការចែកចាយខិត្តប័ណ្ណនៅកម្ពុជាដោយចោទប្រកាន់រដ្ឋាភិបាលថាក្បត់ប្រជាជនឯង ហើយការពារផលប្រយោជន៍របស់វៀតណាម ។ តុលាការបានកាត់ឱ្យពួកគាត់ជាប់ទោស បើទោះជាមិនមានភស្តុតាងណាមួយភ្ជាប់ពួកគេដោយផ្ទាល់ទៅនឹងខិត្តប័ណ្ណនោះក្តី ហើយបានផ្តន្ទាទោសឱ្យអ្នកទាំងបីនោះជាប់ពន្ធនាគាររយៈពេលប្រាំមួយខែ ។ មិនមានសាក្សីណាម្នាក់បានចូលខ្លួនមកបំភ្លឺនៅក្នុងសវនាការនោះទេ ។ នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៧ ការិយាល័យបានឃ្លាំមើលសវនាការកាត់ក្តី លោក ទៀង ណារិទ្ធិ ជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យមួយ ពីបទផ្សាយព័ត៌មានមិនពិត ។ គាត់ត្រូវបានតុលាការកាត់ឱ្យជាប់ពន្ធនាគាររយៈពេលពីរឆ្នាំកន្លះ និងពិន័យជាប្រាក់ចំនួន៥លានរៀល ចំពោះការនិពន្ធសៀវភៅមួយក្បាលដែលមិនទាន់បោះពុម្ពផ្សាយនៅឡើយ ដែលសៀវភៅនោះបានរិះគន់យ៉ាងខ្លាំងដល់រដ្ឋាភិបាល ។ ការិយាល័យបានតាមឃ្លាំមើលផងដែរ លើករណីលោក សឿន សាវ៉ាន់ ប្រធានសមាគមមិត្តភាពខ្មែរកម្ពុជាក្រោមនៅខេត្តតាកែវ ដែលបានធ្វើការទាមទារឱ្យដោះលែងខ្មែរក្រោមមួយក្រុមដែលមានមនុស្សសែសិបប្រាំបីនាក់ ត្រូវបានឃុំខ្លួនបន្ទាប់ពីបានឆ្លងដែនពីវៀតណាមចូលមកក្នុងប្រទេសកម្ពុជានៅក្នុងខែកុម្ភៈ ឆ្នាំ២០០៧ ។ លោកសឿន ត្រូវតុលាការចោទប្រកាន់ពីបទផ្សាយព័ត៌មានមិនពិត ដែលគេចោទថា គាត់បានហៅមនុស្សមួយក្រុមនោះថាជា " ជនភៀសខ្លួន " ក្នុងសេចក្តីថ្លែងការណ៍មួយប្រាប់អ្នកសារព័ត៌មាន ។ អយ្យការអះអាងថា សេចក្តីថ្លែងការណ៍នេះមានបំណងផ្សាយព័ត៌មានមិនពិតប្រាប់សាធារណៈជន ដើម្បីធ្វើឱ្យខូចសណ្តាប់ធ្នាប់សាធារណៈ ដោយហេតុថារដ្ឋាភិបាលកម្ពុជាបានចាត់ទុកខ្មែរក្រោមជាប្រជាពលរដ្ឋខ្មែរ ។ ករណីរបស់គាត់កំពុងស្ថិតក្នុងតុលាការខេត្តតាកែវ ។

១២. ដូចនៅក្នុងប៉ុន្មានឆ្នាំកន្លងទៅនេះ គេសំគាល់ឃើញមានការរិតត្បិតលើការអនុវត្តន៍របស់ប្រជាពលរដ្ឋ នូវសិទ្ធិប្រជុំដោយសន្តិវិធីរបស់ខ្លួន ដែលបានធានាការពារដោយរដ្ឋធម្មនុញ្ញ ។ នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៧ ការិយាល័យបានធ្វើអន្តរាគមន៍ដើម្បីដោះស្រាយការប្រឈមមុខគ្នារវាងនគរបាលនិងព្រះសង្ឃខ្មែរក្រោមមួយក្រុម ដែលធ្វើការតវ៉ានៅខាងក្រៅស្ថានទូតវៀតណាម ដោយចោទថាមានការគាបសង្កត់លើព្រះសង្ឃនៅវៀតណាម ។ ពីរថ្ងៃក្រោយមក គេបានប្រទះឃើញព្រះសង្ឃមួយអង្គក្នុងចំណោមព្រះសង្ឃដែលធ្វើការតវ៉ានោះ សុគតនៅនឹងវត្តដែលព្រះអង្គគង់នៅក្នុង

ខេត្តកណ្តាល ។ ទោះបីជាមានស្នាមអាវុធដាច់ជាច្រើនកន្លែងនៅលើកព្រះអង្គក្តី ក៏នគរបាលបានធ្វើការសន្និដ្ឋានថា ការសុគតនេះថាជាករណីអត្តឃាត ។ នៅថ្ងៃទី២១ ខែមីនា ព្រះសង្ឃជាច្រើនអង្គ បានព្យាយាមរៀបចំពិធីបុណ្យសព ព្រះសង្ឃអង្គនោះនៅវត្តដែលព្រះអង្គគង់នៅជាច្រើនដង តែត្រូវបាននគរបាលរារាំងមិនឱ្យធ្វើ ។ បន្ទាប់ពីបាតុកម្មនៅក្នុងខែកុម្ភៈឆ្នាំ២០០៧ ដែលកាសែតបរទេសជាច្រើនបានចុះផ្សាយ អង្គការខ្មែរក្រោមនានាបានស្ថិតក្រោមការគាប-សង្កត់កាន់តែខ្លាំងឡើង ពីសំណាក់អាជ្ញាធរនានាដើម្បីបង្អន់សកម្មភាពរបស់ពួកគេ ។ នៅថ្ងៃទី៨ ខែ មិថុនា ឆ្នាំ ២០០៧ ក្រសួងវប្បធម៌និងសាសនា និងព្រះតេជគុណ នួន ង៉ែត ព្រះសង្ឃរាជក្រុងភ្នំពេញ បានចេញសេចក្តីណែនាំមួយ បញ្ជាព្រះសង្ឃទាំងអស់ឱ្យបញ្ឈប់ការចូលរួមក្នុងបាតុកម្មសាធារណៈ ។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមួយរូប បានចោទសួរជាសាធារណៈអំពីធម្មនុញ្ញភាព នៃសេចក្តីណែនាំនេះ ។ ម្យ៉ាងវិញទៀត ព្រះសង្ឃត្រូវគេរារាំងមិនឱ្យចូលរួមក្នុងការបោះឆ្នោត ។

១៣. ការិយាល័យបានធ្វើអន្តរាគមន៍ផងដែរ ទៅសាលាខេត្តរតនគិរី ដើម្បីស្នើសុំឱ្យមានការបំភ្លឺអំពីមូលហេតុ នៃការហាមប្រាមមិនឱ្យបើកសិក្ខាសាលាដែលបានគ្រោងទុកជាមុន ការប្រមូលសហគមន៍មូលដ្ឋាន និងមន្ត្រីឃុំ-សង្កាត់ និងមន្ត្រីស្រុកនានា មកពិភាក្សាអំពីការអនុវត្តន៍ច្បាប់ភូមិបាល ។ ក្រោយពីសិក្ខាសាលានេះ មនុស្សមួយក្រុមតូច បានដើរដង្ហែរជាក្បួនដោយសន្តិវិធីដែលរៀបចំឡើងនៅទីរួមខេត្តនេះ ដោយអំពាវនាវឱ្យមានការអនុវត្តន៍ប្រកបដោយប្រសិទ្ធិភាពនូវសេចក្តីថ្លែងការណ៍របស់នាយករដ្ឋមន្ត្រីពាក់ព័ន្ធនឹងការការពារដីធ្លី និងព្រៃឈើក្នុងខេត្តនេះ ។ ការដើរដង្ហែរជាក្បួននេះ ដែលមិនបង្កការគំរាមកំហែងដល់សន្តិសុខនោះ ត្រូវបានហាមឃាត់ ហើយក្រោយមកត្រូវបានបំបែកដោយក្រុមឡានទឹកពន្លត់អគ្គិភ័យ ។

១៤. នៅក្នុងឆ្នាំ២០០៧ ការិយាល័យមានកង្វល់កាន់តែខ្លាំងឡើងៗអំពីការប្រព្រឹត្តរបស់អាជ្ញាធរនានាលើសកម្មជនខ្មែរក្រោមដែលរស់នៅកម្ពុជា ។ ពាក្យថាខ្មែរក្រោមតាមន័យត្រង់ គឺខ្មែររស់នៅតំបន់ទំនាប ហើយដែលគេនិយាយសំដៅដល់ជនជាតិភាគតិចខ្មែររស់នៅវៀតណាមខាងត្បូង ។ សហគមន៍ខ្មែរក្រោមដែលមានមនុស្សច្រើនរស់នៅកម្ពុជា ត្រូវបានរដ្ឋាភិបាលបញ្ជាក់ថាពួកគេ គឺជាប្រជាពលរដ្ឋខ្មែរតាមស្មារតីរបស់រដ្ឋធម្មនុញ្ញ ។

១៥. នៅឆ្នាំដែលមហាសន្និបាតបានអនុម័តសន្ធិសញ្ញាអន្តរជាតិថ្មីមួយ ដែលដាក់ការបាត់ខ្លួនដោយបង្ខំនៅក្រៅច្បាប់ ការិយាល័យបានតាមដានករណីព្រះតេជគុណ ទឹម សាខន ជាព្រះសង្ឃខ្មែរកម្ពុជាក្រោម និងជាចៅអធិការវត្តមួយនៅខេត្តតាកែវ គង់នៅកម្ពុជាចាប់តាំងពីឆ្នាំ១៩៧៩រហូតមក ។ នៅថ្ងៃទី៣០ខែមិថុនាព្រះតេជគុណ ទឹម សាខន ត្រូវបានគេចាប់ផ្សឹកតាមបញ្ជារបស់ព្រះសង្ឃរាជ ទេព វង្ស ដោយចោទប្រកាន់ថា " បានប្រព្រឹត្តបំពានលើវិន័យសង្ឃ ធ្វើឱ្យខូចដល់ទំនាក់ទំនងជាតិនិងអន្តរជាតិ ជាពិសេសរវាងកម្ពុជានិងវៀតណាម តាមរយៈការប្រើប្រាស់វត្តធ្វើជាកន្លែងឃោស-

នា ដែលធ្វើឱ្យប៉ះពាល់ដល់ព្រះពុទ្ធសាសនា និងកិត្តិយសរបស់ព្រះពុទ្ធសាសនា ”។ ព្រះសង្ឃអង្គនេះ បានផ្តល់កន្លែងជ្រកកោនដល់ព្រះសង្ឃខ្មែរក្រោម ដែលអះអាងថាភៀសខ្លួនពីការធ្វើទុក្ខបុកម្នេញនៅវៀតណាម ហើយបានផ្សព្វ-ផ្សាយព័ត៌មានអំពីសិទ្ធិខ្មែរក្រោម ។ នៅពេលកំពុងចាប់ផ្សឹក វត្តនោះត្រូវបាននគរបាលឡោមព័ទ្ធ ហើយមានសេចក្តីរាយការណ៍ថាព្រះតេជគុណ ទឹម សាខន ត្រូវបានបុរសស្លៀកពាក់ស៊ីវិលដឹកចេញទៅតាមឡាន ។ ការិយាល័យបានសរសេរលិខិតពីរលើកទៅរដ្ឋាភិបាល ស្នើសុំឱ្យផ្តល់ព័ត៌មានអំពីទីកន្លែងគង់នៅរបស់ព្រះសង្ឃទឹម សាខន ប៉ុន្តែមិនបានទទួលការឆ្លើយតបវិញឡើយ ។ ក្រោយពីគ្មានព័ត៌មានជាក់លាក់យ៉ាងយូរមក ទើបលេចឮដំណឹងថា ព្រះអង្គត្រូវនគរបាលឃុំព្រះកាយនៅវៀតណាម ។ ការនិរទេសព្រះតេជគុណ ទឹម សាខន គឺជាការរំលោភជាក់ស្តែងលើរដ្ឋធម្មនុញ្ញដែលហាមប្រាមការនិរទេសប្រជាពលរដ្ឋខ្មែរ ប្រសិនបើខ្មែរក្រោមមានឋានៈជាប្រជាពលរដ្ឋខ្មែរនោះ ។ ប្រសិនជាមិនមានឋានៈនេះទេ អញ្ចឹងខ្មែរក្រោមដែលអះអាងថាត្រូវគេធ្វើទុក្ខបុកម្នេញ មានសិទ្ធិស្វែងរកឋានៈជាជនភៀសខ្លួនស្របតាមអនុសញ្ញាស្តីពីឋានៈរបស់ជនភៀសខ្លួន ដែលកម្ពុជាគឺជាភាគីមួយនៃអនុសញ្ញានេះផងដែរ ។

១៦. ការិយាល័យតាមសង្កេតមើលបាតុកម្មតូចមួយ ដែលមានព្រះសង្ឃខ្មែរក្រោមចំនួន៤៨ អង្គនៅខាងមុខស្ថានទូតវៀតណាម ស្នើឱ្យទទួលញត្តិមួយដែលអំពាវនាវសុំឱ្យអាជ្ញាធរវៀតណាមប្រគល់ដីធ្លី ដែលខ្លួនបានរឹបអូសយកក្នុងឆ្នាំ១៩៧៨ នៅពេលដែលមានជំលោះប្រដាប់អាវុធតាមព្រំដែន រវាងទាហានខ្មែរក្រហមនិងកងទ័ពវៀតណាម ។ នេះជាបាតុកម្មដោយសន្តិវិធី តែត្រូវបានបំបែកយ៉ាងព្រៃផ្សៃដោយកងកំលាំងសន្តិសុខ ដោយប្រើប្រាស់ដំបងប្រឆាំងកុប្បកម្មនិងដំបងឆក់ ។ ព្រះសង្ឃពីរអង្គបានរងរបួសជាទម្ងន់ ។ ការិយាល័យមានកង្វល់ថា ការបង្ក្រាបដោយហឹង្សាទៅលើការប្រជុំដោយសន្តិវិធីនៅក្នុងបរិបទនៃបញ្ហានយោបាយ ដែលវេទយិតភាពបំផុតពាក់ព័ន្ធនឹងទំនាក់ទំនងរវាងកម្ពុជានិងវៀតណាម អាចនឹងនាំឱ្យមានជំលោះនិងអំពើហឹង្សាខ្លាំងឡើងថែមទៀត រវាងសហគមន៏កម្ពុជានិងសហគមន៏វៀតណាមនៅទីក្រុង ។ ការិយាល័យបានព្យាយាមជួបពិភាក្សាជាមួយអាជ្ញាធរកម្ពុជា និងមន្ត្រីស្ថានទូតវៀតណាម ដើម្បីរិះរកវិធីដោះស្រាយជំលោះទាំងនេះដោយសន្តិវិធី ។

១៧. ការិយាល័យបានលើកជាមួយតុលាការ និងអាជ្ញាធរនគរបាលខេត្តរតនគីរី អំពីករណីដែលសមាជិកបីរូប នៃសហគមន៏ជនជាតិដើមភាគតិចកាឈុគ ត្រូវបានចាប់ខ្លួនដោយសង្ស័យពីបទជួញដូរមនុស្ស ។ បុរសទាំងនេះបានផ្តល់ជំនួយមនុស្សធម៌ដល់ *ម៉ុងតាញ៉ាត(ពួកកុលសម្ព័ន្ធភ្នំ)* (ជនជាតិដើមភាគតិចនៅភាគឦសាននៃប្រទេសកម្ពុជា និងនៅតំបន់ខ្ពង់រាបកណ្តាលនៃប្រទេសវៀតណាម) ដែលស្ថិតក្នុងអម្បូរក្រុមជាតិពន្ធុដូចគ្នា បន្ទាប់ពីពួកគេបានឆ្លងកាត់ព្រំដែនពីប្រទេសវៀតណាមដើម្បីស្វែងរកការការពារ ។ ពួកម៉ុងតាញ៉ាត(ពួកកុលសម្ព័ន្ធភ្នំ) តែងតែឆ្លងកាត់ព្រំដែនចូលមកប្រទេសកម្ពុជា ដើម្បីស្វែងរកសិទ្ធិជ្រកកោន ដោយបានចោទថា អាជ្ញាធរវៀតណាមធ្វើទុក្ខបុកម្នេញពួកគាត់ ។ បុរស

កាឈុតបីនាក់នេះបានជួយដល់ពួកម៉ុងតាញ៉ាត ក្នុងការទាក់ទងជាមួយមន្ត្រីការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកជនភៀសខ្លួននៅភ្នំពេញ ។ បុរសទាំងបីនាក់នេះត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលប្រាំមួយខែ ។

១៨. ការិយាល័យបានបន្តឃ្លាំមើលការរំលោភសិទ្ធិសេរីភាពក្នុងការសំដែងមតិ ជាពិសេសអ្នកកាសែត ។ ក្នុងខែមិថុនា ឆ្នាំ២០០៧ រដ្ឋាភិបាលបានហាមប្រាមការផ្សព្វផ្សាយរបាយការណ៍មួយ ដែលបោះពុម្ពផ្សាយដោយអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិមួយ ដែលមានឈ្មោះថា Global Witness ដែលបរិយាយលំអិតអំពីការចោទថាមានជាប់ពាក់ព័ន្ធនឹងមន្ត្រីរដ្ឋាភិបាលមួយចំនួននិងក្រុមគ្រួសាររបស់ពួកគេក្នុងសកម្មភាពកាប់ឈើខុសច្បាប់ ។ អ្នកកាសែតត្រូវបានគេព្រមានមិនឱ្យរាយការណ៍ ឬចុះផ្សាយបន្តព័ត៌មានដែលដកស្រង់ចេញពីរបាយការណ៍ ហើយកាសែតភាសាបារាំងមួយឈ្មោះថា*កាំបូស៊្ញ័រ* ត្រូវបានបិទទ្វារ ដោយក្រុមប្រឹក្សារបស់ខ្លួនបន្ទាប់ពីមានការធ្វើកូដកម្មរយៈពេលពីរថ្ងៃដោយអ្នកកាសែតដែលធ្វើការតវ៉ាអំពីការបណ្តេញបុគ្គលិករបស់ខ្លួនម្នាក់ ដែលបានរាយការណ៍លំអិតអំពីរបាយការណ៍របស់អង្គការ Global Witness ។ ការិយាល័យបានតាមឃ្លាំមើលនិងបានផ្តល់ការការពារដល់បុគ្គលមួយចំនួនក្នុងបរិបទនៃសកម្មភាពបំភិតបំភ័យជាច្រើនពាក់ព័ន្ធនឹងរបាយការណ៍នេះ ។

១៩. ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលបានធ្វើឡើងនៅថ្ងៃទី១ ខែមេសា ឆ្នាំ២០០៧ ក្នុងលក្ខណៈដែលអ្នកសង្កេតការណ៍បានសំគាល់ឃើញជាទូទៅថាមានភាពត្រឹមត្រូវ ។ ការិយាល័យបានតាមឃ្លាំមើលយុទ្ធនាការឃោសនាបោះឆ្នោត ដែលជាផ្នែកមួយនៃកម្មវិធីសកម្មភាពទ្បេងទាត់របស់ខ្លួន ប៉ុន្តែមិនមានការជ្រើសរើសអ្នកសង្កេតការបោះឆ្នោត ដូចដែលធ្លាប់ធ្វើក្នុងការបោះឆ្នោតមុនៗនោះឡើយ ។ ការិយាល័យOHCHR មានសេចក្តីរីករាយដោយកត់សំគាល់ថា នៅអំឡុងពេលជាច្រើនខែមុនយុទ្ធនាការបោះឆ្នោត បានបង្ហាញថាអំពើហឹង្សាខាងនយោបាយមានការថយចុះ ដូចជាការសំលាប់ ឬការវាយប្រហារដោយហឹង្សាផ្សេងៗទៀតទៅលើអ្នកគាំទ្រគណបក្សប្រឆាំងបើប្រៀបធៀបនឹងការបោះឆ្នោតកាលពីលើកមុខ ។ នេះគឺជាការរីកចំរើនមួយគួរឱ្យស្វាគមន៍បំផុត ។

២០. ការិយាល័យបានឃ្លាំមើលផងដែរនូវការកាត់ក្តីសមាជិកគណបក្សប្រឆាំង និងជាអតីតសហនាយករដ្ឋមន្ត្រីព្រះអង្គម្ចាស់នរោត្តរណប្ញទ្ធិ លើការចោទប្រកាន់ដែលមានមន្ទិលពីបទរំលោភលើសេចក្តីទុកចិត្ត ពាក់ព័ន្ធនឹងការលក់ទីស្នាក់ការធំរបស់គណបក្សរណសិរ្សជាតិដើម្បីឯករាជ្យ អព្យាក្រឹត្យ សន្តិភាព និងសហប្រតិបត្តិការកម្ពុជា ដែលហៅ-កាត់ថា [ហ៊្វុនស៊ីនប៉ិច(FUNCINPEC)] ដែលព្រះអង្គបានដឹកនាំរហូតដល់ឆ្នាំ២០០៦ ដោយចោទថា ដើម្បីជាផលប្រ-យោជន៍ផ្ទាល់ខ្លួន ។ ការដោះស្រាយករណីនេះដោយតុលាការគឺជាការសាកល្បងមួយដ៏សំខាន់ នៅក្នុងបរិបទនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅថ្ងៃខាងមុខ អំពីថាតើសេចក្តីសំរេចរបស់តុលាការធ្វើឡើង ដោយផ្អែកលើភស្តុតាងនិងច្បាប់ ឬការពិចារណាផ្សេងទៀតឬយ៉ាងណា ។

២១. នៅក្នុងឆ្នាំនេះ ការិយាល័យបានធ្វើអន្តរាគមន៍ជាមួយរដ្ឋាភិបាលលើករណីជាច្រើន ដែលក្នុងនោះមានការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌទៅលើបុគ្គលក្នុងសកម្មភាពនយោបាយមួយចំនួន បើទោះជាមានភស្តុតាងផ្នែកវេជ្ជសាស្ត្របញ្ជាក់ថា បុគ្គលទាំងនេះមានជម្ងឺសសៃប្រសាទ ដែលអាចបន្ថយការទទួលខុសត្រូវក្តី ។ ប្រព័ន្ធយុត្តិធម៌មិនផ្តល់ការធានាឱ្យបានគ្រប់គ្រាន់ដើម្បីការពារសិទ្ធិរបស់អ្នកដែលមានបញ្ហាសុខភាពផ្លូវចិត្តឡើយ ។

## ឥ. នីតិរដ្ឋនិងវិស័យយុត្តិធម៌

២២. ការិយាល័យបានបន្តតាមដានយ៉ាងជិតដល់ចំពោះការរីកចំរើនក្នុងវិស័យយុត្តិធម៌ ជាវិស័យមួយដែលការិយាល័យបានប្តេជ្ញាចិត្តក្នុងការយកចិត្តទុកដាក់និងបានប្រើប្រាស់ធនធានយ៉ាងច្រើននៅក្នុងរយៈកាល១៤ឆ្នាំកន្លងមកនេះ ។ កម្មវិធីនីតិរដ្ឋរបស់ការិយាល័យធ្វើការជាមួយស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់ស្ថាប័នទាំងនោះ ដើម្បីធានាថា ច្បាប់ទាំងឡាយស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិនិងត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធិភាព ។ បញ្ហាសំខាន់និងលក្ខណៈវិនិច្ឆ័យសំរាប់ការិយាល័យធ្វើការវាយតម្លៃទៅលើប្រព័ន្ធនេះ គឺថាក៏រិតត្រឹមណាដែលអ្នកត្រូវគេរំលោភសិទ្ធិអាចទទួលបានការដោះស្រាយប្រកបដោយប្រសិទ្ធិភាពតាមរយៈតុលាការនោះ ។ ការវាយតម្លៃរបស់ការិយាល័យនោះ គឺករណីនេះកើតមានជាពិសេស ហើយថាអ្នកក្រីក្រ និងងាយទទួលរងគ្រោះជាធម្មតាមិនអាចទទួលបានយុត្តិធម៌តាមរយៈតុលាការឡើយ ។ សិទ្ធិនិងបញ្ញត្តិធានាការពារនីតិវិធីជាមូលដ្ឋាន ត្រូវបានគេរំលោភជាប្រចាំ ជារឿយៗពួកគេតែងតែក្លាយជាជនរងគ្រោះរបស់ប្រព័ន្ធយុត្តិធម៌ ។ ការនេះបង្ហាញអំពីមូលហេតុដែលនាំឱ្យប្រជាជនទូទៅបាត់បង់ជំនឿលើប្រព័ន្ធយុត្តិធម៌ ហើយគេតែងតែចាត់ទុកថាជាយន្តការមួយសំរាប់ឱ្យមានការរំលោភតទៅទៀត ។

២៣. នៅក្នុងឆ្នាំ២០០៧ រដ្ឋាភិបាលបានអនុម័តច្បាប់សំខាន់ៗថែមទៀតនៅក្នុងកម្មវិធីកំណែទម្រង់ច្បាប់របស់ខ្លួន ។ ការចូលជាធរមាននៃក្រមនីតិវិធីរដ្ឋប្បវេណី នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៧ ហើយបន្ទាប់មកមានក្រមនីតិវិធីព្រហ្មទណ្ឌនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៧ ។ ក្រមទាំងនេះគឺជាគ្រឹះដ៏សំខាន់នៅក្នុងទិដ្ឋភាពច្បាប់ថ្មី ។ ក្រោយពីការអនុម័តក្រមទាំងនេះ បានចាប់ផ្តើមកម្មវិធីបណ្តុះបណ្តាលចៅក្រមនិងព្រះរាជអាជ្ញា ក្រោមការឧបត្ថម្ភពីក្រសួងយុត្តិធម៌ ដើម្បីឱ្យបានយល់ដឹងអំពីខ្លឹមសារនៃក្រមទាំងនេះ ។ ការិយាល័យបានចាប់ផ្តើមឃ្លាំមើលការអនុវត្តន៍ក្រមនីតិវិធីព្រហ្មទណ្ឌ ហើយកំពុងរិះរកវិធីដើម្បីសហការជាមួយស្ថាប័ននានាដែលពាក់ព័ន្ធ ដើម្បីជួយដល់ការបណ្តុះបណ្តាលចៅក្រមអំពីក្រមនេះ ។

២៤.	ការិយាល័យនៅតែរក្សាទំនាក់ទំនងការងារជាមួយចៅក្រមនិងព្រះរាជអាជ្ញានានា ដោយគោរពទាំងស្រុង នូវឯករាជ្យភាពរបស់ពួកគេ និងបានបន្តពិភាក្សាអំពីកង្វល់ទាំងឡាយដែលទាក់ទងនឹងករណីបុគ្គលនីមួយៗ ដែលឆ្លងកាត់ប្រព័ន្ធតុលាការ ។ កង្វល់មួយដែលមានជាយូររហូតមក ដែលចៅក្រមជាច្រើនបានលើកឡើង បានក្លាយជាផលវិបាកយ៉ាងធ្ងន់ធ្ងរ និងមិនសមាមាត្រទៅលើអនីតិជនក្នុងមាត្រា៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។ ច្បាប់នេះបានអនុម័តក្នុងឆ្នាំ២០០២ បានដកចេញទាំងឆន្ទានុសិទ្ធិដែលចៅក្រមមានកន្លងមក ក្រោមបទបញ្ញត្តិព្រហ្មទណ្ឌនៃបទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជា ក្នុងសម័យអន្តរកាល (ដែលជាទូទៅគេស្គាល់ថា ជាច្បាប់របស់អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិ ឬច្បាប់អ៊ុនតាក់) ដើម្បីគិតពីអាយុរបស់ជនល្មើសក្នុងស្ថានសំរាល និងកាតព្វកិច្ចដែលចៅក្រមត្រូវតែបន្ថយទោសគុកពាក់កណ្តាល ចំពោះអនីតិជនដែលមានអាយុក្រោមដប់ប្រាំបីឆ្នាំ ។ ដូច្នេះច្បាប់ឆ្នាំ២០០២ ដែលអនុវត្ត ទៅលើអនីតិជនរហូតមក ទៅជាការរំលោភយ៉ាងជាក់ស្តែងទៅលើមាត្រា៣៧ (ខ) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលបានធានាការពារក្រោមរដ្ឋធម្មនុញ្ញមាត្រា៣១ និងមាត្រា៤៨ ។ ជាលទ្ធផល ចៅក្រមមួយចំនួននៅខេត្តខ្លះបានបន្តអនុវត្តច្បាប់អ៊ុនតាក់ ដែលនាំឱ្យការអនុវត្តច្បាប់នេះមិនដូចគ្នានិងមិនស្របគ្នា ។ ការិយាល័យបានចូលរួមក្នុងសិក្ខាសាលាមួយដែលបានរៀបចំឡើងដោយក្រសួងយុត្តិធម៌និងមូលនីធិសហប្រជាជាតិដើម្បីកុមារ(UNICEF) ពាក់ព័ន្ធ នឹងសេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជន ជាកន្លែងដែលបញ្ហានេះត្រូវបានលើកមកពិភាក្សា ។

២៥.	ក្នុងករណីនេះ ការិយាល័យនិងមូលនីធិសហប្រជាជាតិដើម្បីកុមារ(UNICEF) បានផ្តល់ការគាំទ្រ និងផ្តល់យោបល់ដល់ក្រុមមេធាវីនិងអង្គការក្រៅរដ្ឋាភិបាលខាងសិទ្ធិកុមារឱ្យរៀបចំសំណើអនុសាសន៍ជូនក្រុមប្រឹក្សាធម្មនុញ្ញសុំឱ្យពិនិត្យធម្មនុញ្ញភាពនៃច្បាប់ឆ្នាំ២០០២ ដោយពិចារណាទៅលើកាតព្វកិច្ចទាំងឡាយដែលបានធានាការពារដោយរដ្ឋធម្មនុញ្ញក្រោមអនុសញ្ញាស្តីពីសិទ្ធិកុមារ ។ ប្រជាពលរដ្ឋខ្មែរគ្មានសិទ្ធិធ្វើញត្តិដោយផ្ទាល់ទៅក្រុមប្រឹក្សាធម្មនុញ្ញឡើយ ដូច្នេះហើយទើបសំណើរនេះត្រូវដាក់ជូនទៅបុគ្គលច្រើនជាង២០០នាក់ ជាបុគ្គលក្នុងតំណែងឬ ជាសមូភាពដែលមានសិទ្ធិធ្វើញត្តិរួមទាំងព្រះមហាក្សត្រ ដែលបញ្ជូនញត្តិនេះដោយមេត្រីភាពបន្តទៅក្រុមប្រឹក្សាធម្មនុញ្ញ ។

២៦.	លុះក្រោយមក ក្រុមប្រឹក្សាធម្មនុញ្ញបានចេញសេចក្តីសំរេចមួយចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ បង្កើតគោលការណ៍គ្រឹះមួយក្នុងការការពារសិទ្ធិមនុស្សនៅកម្ពុជា ។ ទោះបីជាក្រុមប្រឹក្សានេះបានសំរេចថាច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋមានធម្មនុញ្ញភាពយ៉ាងណាក៏ដោយ ក៏ក្រុមប្រឹក្សាបានសំរេចបែបនេះ ដោយផ្អែកលើមូលដ្ឋានថា ច្បាប់នេះមិនមានគោលបំណងលុបចោលបញ្ញត្តិទាំងឡាយ ដែលផ្តល់កិច្ចការពារដល់ជនល្មើសជាអនីតិជនក្នុងបញ្ញត្តិច្បាប់អ៊ុនតាក់ឡើយ ព្រោះថាការធ្វើដូច្នេះបានរំលោភលើរដ្ឋធម្មនុញ្ញនិងអនុសញ្ញាស្តីពីសិទ្ធិកុមារ ។ លើសពីនេះទៀត ក្រុមប្រឹក្សាធម្មនុញ្ញបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងសេចក្តីសំរេចរបស់ខ្លួនថា សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ

នានា ដែលកម្ពុជាគឺជាភាគីនោះ គឺជាផ្នែកមួយនៃច្បាប់ជាតិ ដូច្នេះហើយចៅក្រមនៅតាមតុលាការនានាត្រូវតែអនុវត្ត ដោយផ្ទាល់ ។ ការិយាល័យបានស្វាគមន៍ជាសាធារណៈ នូវសេចក្ដីសំរេចដ៏សំខាន់នេះ ហើយបានផ្សព្វផ្សាយ និងពន្យល់ អំពីសេចក្ដីសំរេចនេះ តាមរយៈសិក្ខាសាលាជាតិមួយសំរាប់ចៅក្រមនិងព្រះរាជអាជ្ញាដែលបានរៀបចំឡើងដោយ សហការគ្នារវាងក្រសួងយុត្តិធម៌ និងមូលនិធិសហប្រជាជាតិដើម្បីកុមារ(UNICEF) ។ ការិយាល័យមានសេចក្ដី រីករាយ ដែលបច្ចុប្បន្ននេះ ចៅក្រមនានាកំពុងអនុវត្តសេចក្ដីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៅក្នុងការវិនិច្ឆ័យរបស់ ខ្លួន ។ ក្រុមប្រឹក្សាធម្មនុញ្ញគឺជាស្ថាប័នមួយដ៏សំខាន់ ប៉ុន្តែជារឿយៗត្រូវគេចាត់ទុកថាមិនសំខាន់ដែលតួនាទីរបស់ ស្ថាប័ននេះ ក្នុងការការពាររដ្ឋធម្មនុញ្ញនិងសិទ្ធិមនុស្សនៅកម្ពុជា គួរតែបានទទួលស្គាល់និងគោរពឱ្យបានទូលំទូលាយ ជាងនេះថែមទៀត ។

២៧. នៅចុងឆ្នាំនេះការិយាល័យបានជួបប្រជុំជាមួយតំណាងនានានៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ដើម្បីរួមគ្នារិះរកវិធីផ្សេងៗដើម្បីបង្កើតកិច្ចសហប្រតិបត្តិការ ។ យើងបានកំណត់យកវិស័យមួយចំនួន រួមមានការ បង្កើតមូលដ្ឋានទិន្នន័យស្ដីពីសិទ្ធិមនុស្ស, ការអប់រំ និងបណ្ដុះបណ្ដាល, ការគាំទ្រដល់ក្រសួងអប់រំក្នុងវិស័យអប់រំសិទ្ធិម- នុស្ស និងការជួយឧបត្ថម្ភដល់អង្គភាពគ្រប់គ្រងផែនការនៃក្រុមប្រឹក្សានេះ ។

២៨. កិច្ចខិតខំប្រឹងប្រែងដ៏សកម្មជាថ្មីរបស់ការិយាល័យ ដើម្បីបង្កើតទំនាក់ទំនងការងារជាមួយប្រធានគណៈកម្មា- ធិការសិទ្ធិមនុស្សកម្ពុជា នៅត្រីមាសចុងក្រោយនេះ មិនទាន់មានការឆ្លើយតបនៅឡើយទេ ។

## ឃ. និទ្ទណ្ឌភាព

២៩. ការប្រយុទ្ធប្រឆាំងនឹងនិទ្ទណ្ឌភាព គឺជាបញ្ហាអាទិភាពមួយក្នុងចំណោមបញ្ហាអាទិភាពធំៗរបស់ឧត្ដមស្នងការ អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សទូទាំងពិភពលោក ។ ចាប់តាំងពីខែវិច្ឆិកាឆ្នាំ២០០៧ ការិយាល័យ បាន ចាប់ផ្ដើមឃ្លាំមើលកិច្ចដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ECCC) ដែលបានបង្កើតឡើង ដើម្បីវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះ ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងសម័យកាលដ៏ខ្មៅងងឹត(១៩៧៥-១៩៧៨) ។ តួនាទីរបស់ការិយាល័យនៅក្នុងវិស័យ នេះគឺតាមឃ្លាំមើលដំណើរការជម្រះក្ដីរបស់តុលាការខ្មែរក្រហម (ECCC) ដើម្បីកត់សំគាល់អំពីទំលាប់អនុវត្តល្អ និង នីតិវិធីគំរូ ដែលអាចយកមកធ្វើជាប្រភពសំរាប់ការយល់ដឹង ការអប់រំ និងការលើកទឹកចិត្តដល់ចៅក្រម ព្រះរាជអាជ្ញា

និងមេធាវី នៅក្នុងប្រព័ន្ធយុត្តិធមិទាំងមូល និងចូលរួមផ្តល់ជាកំលាំងដើម្បីដោះស្រាយឧក្រិដ្ឋកម្មដែលកើតមាននៅក្នុងអំឡុងពេលប៉ុន្មានឆ្នាំថ្មីៗនេះ ដែលនៅមិនទាន់បានផ្តន្ទាទោសនៅឡើយ ។

៣០. បញ្ហានិទ្ទណ្ឌភាពត្រូវបានកត់សំគាល់ដោយតំណាងពិសេសមុនៗនៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជាថា ជាឧបសគ្គធំបំផុតតែមួយគត់ ដែលធ្វើឱ្យនីតិរដ្ឋចុះខ្សោយនៅកម្ពុជា ។ ក្នុងបញ្ហានេះ នៅឆ្នាំ២០០៧ បានបង្ហាញពីការរីកចំរើនជាវិជ្ជមាន ក្នុងការដោះស្រាយឧក្រិដ្ឋកម្មមួយចំនួននៅក្នុងអតីតកាល ។ លទ្ធផលជាវិជ្ជាមាននោះគឺ អាជ្ញាធរបានចាប់ខ្លួនអតីតទាហានខ្មែរក្រហមបីរូប ដែលគេចោទថាមានជាប់ពាក់ព័ន្ធក្នុងការសំលាប់អ្នកជំនាញដោះមីនជនជាតិអង់គ្លេសម្នាក់ និងអ្នកបកប្រែរបស់គាត់ម្នាក់ជនជាតិខ្មែរក្នុងឆ្នាំ ១៩៩៦ ។

៣១. នៅរដូវក្តៅនេះ តុលាការខ្មែរក្រហម(ECCC) បានអនុម័តវិធានផ្ទៃក្នុងរបស់ខ្លួន បានបន្តធ្វើការចាប់ខ្លួនមេដឹកនាំបួននាក់ទៀតនៃអតីតរបបកម្ពុជាប្រជាធិបតេយ្យ ហើយបានបើកសវនាការលើកដំបូងរបស់ខ្លួនលើករណីនៃអតីតប្រធានមជ្ឈមណ្ឌលសួរចំលើយនិងប្រហារជីវិត ស ២១ ។ ការរីកចំរើនទាំងនេះ បានបង្កើតកំលាំងវិជ្ជមានថ្មីមួយ នៅតុលាការខ្មែរក្រហម(ECCC) ដែលបានជួយសម្រួលដល់កិច្ចសហប្រតិបតិការរវាងកម្ពុជានិងសមាសធាតុអន្តរជាតិនានា ហើយបានឮសំលេងខ្ទរខ្ទាដល់សាធារណៈជនទូទៅ នៅគ្រាដំបូងបង្អស់ក្នុងប្រវត្តិសាស្រ្តនៃប្រទេសកម្ពុជា មន្ត្រីសាធារណៈជាន់ខ្ពស់មួយចំនួនត្រូវបានចាប់ឱ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលពួកគេបានប្រព្រឹត្តក្នុងអតីតកាល ។

៣២. ទោះជាយ៉ាងណាក៏ដោយ ឆ្នាំ២០០៧ បានបង្ហាញឱ្យឃើញពីការដើរថយក្រោយយ៉ាងខ្លាំង ឬគ្មានការរីកចំរើនក្នុងការនាំខ្លួនទៅកាត់ទោសចំពោះជនទាំងឡាយដែលទទួលខុសត្រូវក្នុងករណីឃាតកម្មដែលមិនទាន់បានដោះស្រាយនៅឡើយ ដែលមានក្នុងបញ្ជីដ៏វែងតាំងពីឆ្នាំ១៩៩៣ ។ នៅក្នុងបញ្ជីនេះ មានករណីឃាតកម្មលើលោកជា វិជ្ជា ប្រធានសហជីពកម្មករ គឺជាករណីស្រួចស្រាវជាងគេបំផុត ។ ករណីទាំងនេះ ក៏ដូចជាបាតុភូតនៃនិទ្ទណ្ឌភាព គឺជាឫសគល់ និងជាផលវិបាកអវិជ្ជមានសំរាប់នីតិរដ្ឋនិងយុត្តិធមិក្នុងប្រទេសកម្ពុជា ត្រូវបានធ្វើការវិភាគលំអិតនៅក្នុងរបាយការណ៍មួយក្នុងឆ្នាំ២០០៥ របស់តំណាងពិសេសនៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ដែលជាការរួមចំណែកដ៏សំខាន់សំរាប់ការយល់ដឹងអំពីលំនាំនៃនិទ្ទណ្ឌភាពដែលនៅតែមាននៅកម្ពុជា ។

៣៣. នៅក្នុងខែមេសា ឆ្នាំ២០០៧ ការិយាល័យបានឃ្លាំមើលការប្តឹងឧទ្ធរណ៍របស់ ប៊ិន សំណាង និងសុខ សំអឿន ដែលត្រូវបានតុលាការកាត់ទោសពីបទធ្វើឃាតលោក ជា វិជ្ជា ។ សាលាឧទ្ធរណ៍បានសំរេចតំកល់ទោសនេះ ទោះបីជាមានភស្តុតាងយ៉ាងលើសលុប ដែលបានបង្ហាញថាបុរសទាំងនេះ ជាជនស្លូតត្រង់ក៏ដោយ ។ ករណីនេះ ជានិមិត្តរូប

បង្ហាញអំពីនិទ្ទណ្ឌភាពចំពោះឧក្រិដ្ឋកម្មដែលទំនងជាពាក់ព័ន្ធនឹងទិដ្ឋភាពនយោបាយ ឯករាជ្យភាពនៃអំណាចតុលាការ សមត្ថភាពរបស់តុលាការក្នុងការដោះស្រាយប្រកបដោយប្រសិទ្ធិភាពចំពោះការរំលោភសិទ្ធិមនុស្ស និងចំពោះកង្វល់ដ៏ធ្ងន់ធ្ងរដែលការិយាល័យលើកឡើងអំពីសេរីភាពខាងសហជីពនៅកម្ពុជា ។ បន្ថែមលើករណីឃាតកម្មលើ លោក ជា វិជ្ជា និងករណីឃាតកម្មលើលោក រស់ សុវណ្ណារ៉េត ក្នុងឆ្នាំ២០០៤ ការិយាល័យបានតាមឃ្លាំមើលករណីឃាតកម្មទីបីលើប្រធានសហជីពកម្មករ លោក ហ៊ី វុទ្ធី ក្នុងខែមីនា ឆ្នាំ២០០៧ ។ លោក ហ៊ី វុទ្ធី គឺជាប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងរោងចក្រមួយក្នុងទីក្រុងភ្នំពេញ ។ ទោះបីជាមានការធ្វើអន្តរាគមន៍ពីការិយាល័យជាមួយក្រសួងមហាផ្ទៃក្តី ក៏ដូចជាគ្មានការរីកចំរើនក្នុងការស្វែងរកជនដៃដល់ក្នុងករណីឃាតកម្មចុងក្រោយបំផុតនេះឡើយ ។ ករណីឃាតកម្មទាំងនេះ មិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពរបស់សកម្មជនសហជីពកម្មករក្នុងការការពារសិទ្ធិការងារប៉ុណ្ណោះទេ ប៉ុន្តែវាបានធ្វើឱ្យសាធារណៈជនបាត់បង់ជំនឿថែមទៀត លើប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ។

## ៦. ដីធ្លីនិងការចិញ្ចឹមជីវិត

៣៤. ការិយាល័យបានបន្តឃ្លាំមើលការផ្តល់សម្បទានដីសេដ្ឋកិច្ច ការវាយតម្លៃលើការអនុវត្តន៍ស្របតាមក្របខ័ណ្ឌច្បាប់ដែលបានចែងដោយច្បាប់ភូមិបាល និងអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច ជាពិសេសលក្ខខណ្ឌជាមុនក្នុងការផ្តល់សម្បទានផ្សេងៗ ដោយរួមទាំងការចុះបញ្ជីដីធ្លី ការពិគ្រោះយោបល់ជាសាធារណៈ និងការវាយតម្លៃអំពីហេតុផលប៉ះពាល់បរិស្ថាន និងសង្គម ។

៣៥. ការិយាល័យបានជួយលោកតំណាងពិសេស ក្នុងការរៀបចំរបាយការណ៍មួយដែលពិពណ៌នាអំពីទស្សនៈវិស័យខាងសិទ្ធិមនុស្សលើសម្បទានដីសេដ្ឋកិច្ច ដែលបានចេញផ្សាយក្នុងខែមិថុនា ឆ្នាំ២០០៧ ។ របាយការណ៍នេះបានរកឃើញថាមានការអនុវត្តន៍មិនបានត្រឹមត្រូវនូវច្បាប់ភូមិបាល និងអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច ហើយដែលជាលទ្ធផលគឺសម្បទានដីសេដ្ឋកិច្ចនៅតែបន្តមានផលប៉ះពាល់អវិជ្ជមានដល់សិទ្ធិមនុស្សរបស់សហគមន៍ជនបទ ។ ការិយា-ល័យបានឃ្លាំមើលករណីជាតួយ៉ាងមួយចំនួនដែលបង្ហាញថាបុគ្គល ឬសហគមន៍ដែលរងគ្រោះ ស្ទើរតែមិនបានទទួលការដោះស្រាយ ទោះជាតាមមធ្យោបាយរដ្ឋបាល ឬតុលាការក្តី ដើម្បីការពារសិទ្ធិរបស់ខ្លួនប្រឆាំងនឹងការអនុវត្តន៍តាមតែទំនើងចិត្ត ហើយថានៅក្នុងករណីភាគច្រើន អាជ្ញាធរពាក់ព័ន្ធ និងប្រព័ន្ធយុត្តិធម៌ មិនការពារសិទ្ធិស្របច្បាប់របស់គាត់ទេ តែបែរងាកមកប្រឆាំងនឹងពួកគាត់ទៅវិញ ។

៣៦.    អនុសាសន៍ជាច្រើន ដែលបានធ្វើឡើងដោយលោកតំណាងពិសេស នៅក្នុងរបាយការណ៍របស់គាត់ស្តីពីសម្បទានដីគោលដៅសេដ្ឋកិច្ច បានបញ្ចូលការពិនិត្យលើសម្បទានដែលមានស្រាប់សំរាប់ការអនុវត្តន៍ស្របតាមច្បាប់ ការកាត់បន្ថយសម្បទានដែលមានទំហំលើសកំណត់ ១០.០០០ ហិកតា និងការបោះពុម្ពផ្សាយព័ត៌មានស្តីពីសម្បទានទាំងអស់ ដែលបានផ្តល់រួចហើយនៅថ្នាក់ជាតិ និងនៅថ្នាក់ខេត្ត ។ ការិយាល័យបានចែករំលែកទស្សនៈអំពីការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច និងបានតាមដានការអនុវត្តន៍អនុសាសន៍ទាំងនេះនៅក្នុងការប្រជុំ និងយន្តការសម្របសម្រួលរវាងប្រទេសអ្នកផ្តល់ជំនួយនិងរដ្ឋាភិបាល ។ អនុសាសន៍ទាំងនេះត្រូវបានលើកឡើងនៅក្នុងសន្ទស្សឃ្លាំមើលរួម ដែលបានអនុម័តយល់ព្រមដោយរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍របស់ខ្លួនក្នុងខែមិថុនាឆ្នាំ២០០៧ ។

៣៧.    ការិយាល័យបានបន្តយកចិត្តទុកដាក់លើការលើកស្ទួយ និងការការពារសិទ្ធិខាងដីធ្លី និងធនធានធម្មជាតិរបស់ជនជាតិដើមភាគតិច ដូចបានទទួលស្គាល់ដោយច្បាប់ភូមិបាល និងច្បាប់ស្តីពីព្រៃឈើ ។ ដីធ្លីរបស់ជនជាតិដើមភាគតិចកាន់តែរួមតូចទៅៗ ដោយសារតែការជួញដូរដីខុសច្បាប់ ការផ្តល់ដីសម្បទាន និងការជំរុញការអភិវឌ្ឍន៍តំបន់ព្រំដែនពិសេស ល្វើសាន្តនៃកម្ពុជា មានវិធានការតិចតួចដើម្បីការពារសិទ្ធិលើដីធ្លីរបស់ជនជាតិដើមភាគតិច និងការតាក់តែងឱ្យបានជាក់លាក់នូវកិច្ចដំណើរការធ្វើប័ណ្ណកម្មសិទ្ធិសមូហភាពមានការយឺតយ៉ាវ ។ នៅក្នុងសន្ទុះនាពេលនេះ បើសិនជារដ្ឋាភិ-បាលមិនចាត់វិធានការតឹងតែងទេ ការិយាល័យមានការព្រួយបារម្ភថាសហគមន៍មូលដ្ឋានភាគច្រើននឹងត្រូវបាត់បង់ដីធ្លីការចិញ្ចឹមជីវិត និងមតរកវប្បធម៌របស់ខ្លួន នៅពេលមានគោលនយោបាយច្បាស់លាស់នោះ ។

៣៨.    ក្នុងខែកុម្ភៈ ឆ្នាំ២០០៧ ការិយាល័យ អង្គការពលកម្មអន្តរជាតិ (ILO) និងវេទិកាអង្គការក្រៅរដ្ឋាភិបាលស្តីពីកម្ពុជា បានរួមគ្នាបើកសិក្ខាសាលាមួយស្តីពីជនជាតិដើមភាគតិច និងសិទ្ធិលើដីធ្លីនៅកម្ពុជា ដែលបានអញ្ជើញតំណាងនានារបស់សហគមន៍ជនជាតិដើមភាគតិច រដ្ឋាភិបាល សង្គមស៊ីវិល ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍ និងអង្គការសហប្រជាជាតិ ។ អ្នកចូលរួមទាំងអស់ រួមមានអ្នករាយការណ៍ពិសេសស្តីពីស្ថានការណ៍សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានរបស់ជនជាតិដើមភាគតិច និងប្រធានវេទិកាអចិន្ត្រៃយ៍របស់អង្គកាសហប្រជាជាតិ ស្តីពីបញ្ហាជនជាតិដើមភាគ-តិច ។ ការិយាល័យក៏បានចូលរួមក្នុងការពិគ្រោះយោបល់ពាក់ព័ន្ធនឹងពង្រាងគោលនយោបាយ ស្តីពីការចុះបញ្ជីដីធ្លីរបស់ជនជាតិដើមភាគតិច ហើយបានសំដែងកង្វល់ថា គោលនយោបាយនេះគួរតែទទួលស្គាល់ និងការពារយ៉ាងពេញទំហឹងនូវសិទ្ធិកម្មសិទ្ធិសមូហភាពដូចមានចែងក្នុងច្បាប់ភូមិបាល ។ នៅក្នុងទិវាអន្តរជាតិ ស្តីពីជនជាតិដើមភាគតិចពិភពលោក ការិយាល័យបានចេញសេចក្តីថ្លែងការណ៍មួយ ដោយគូសបញ្ជាក់អំពីការនៅមានកង្វល់អំពីការការពារនិងការអនុវត្តន៍សិទ្ធិលើដីធ្លីរបស់ជនជាតិដើមភាគតិច និងការខកខានមិនបានអនុវត្តន៍ច្បាប់ភូមិបាល ។ ការិយាល័យបានគាំទ្រឱ្យមានការបើកវេទិកាមួយស្តីពីជនជាតិដើមភាគតិច ដោយផ្តោតការយកចិត្តទុកដាក់លើអភិបាលកិច្ចល្អនិងសិទ្ធិលើដីធ្លី ។

៣៩. ការិយាល័យបានបន្តឃ្លាំមើលការបណ្តេញចេញ និងបញ្ហានានាដែលប៉ះពាល់ដល់សិទ្ធិមានលំនៅដ្ឋានសមរម្យ ។ ការបណ្តេញសហគមន៍ក្រីក្រដោយបង្ខំបានកើតមានជាទូទៅ នៅជុំវិញទីក្រុងភ្នំពេញ ដោយសារសេចក្តីត្រូវការនិងតម្លៃដីឡើងខ្ពស់ ក្រៅពីនេះក៏មានការកើនឡើងនូវករណីនៃការបណ្តេញចេញនៅក្រុងព្រះសីហនុ និងខេត្តឯទៀតដោយសារការពង្រីកទីក្រុង ។ ប្រជាពលរដ្ឋជាច្រើនគ្រួសារត្រូវអាជ្ញាធរក្រុង និងអាជ្ញាធរស្រុកបណ្តេញ-ចេញ ដោយបង្ខំពីលំនៅដ្ឋាន ដើម្បីទុកលទ្ធភាពឱ្យគំរោងអភិវឌ្ឍន៍ឯកជន ។ ការបណ្តេញចេញមួយចំនួនបានធ្វើឡើងបន្ទាប់ពីមានការចរចាជាមួយសហគមន៍មូលដ្ឋាន ដែលស្វែងរកការព្រមព្រៀងគ្នាសមស្របមួយតាមរយៈការទូតទាត់សំណងសមរម្យ ។ ការបណ្តេញចេញផ្សេងទៀតបានធ្វើឡើងដោយប្រើកំលាំងនគរបាល និងទាហានប្រដាប់អាវុធហួសហេតុ ដែលបណ្តាលឱ្យមនុស្សរងរបួស និងធ្វើឱ្យអន្តរាយដល់ទ្រព្យសម្បត្តិ ។ ប្រជាពលរដ្ឋ ដែលគេបណ្តេញចេញជាច្រើនគ្រួសារត្រូវបាត់បង់ផ្ទះសម្បែង ឬបានទៅតាំងទីលំដៅថ្មីនៅតំបន់ឆ្ងាយស្ថិតនៅជាយក្រុងភ្នំពេញ ដែលខ្វះខាតសេវាកម្មចាំបាច់ផ្សេងៗ ហើយបានធ្វើឱ្យពួកគេឃ្លាតឆ្ងាយពីការចិញ្ចឹមជីវិតដែលធ្លាប់មាន ។

៤០. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានជំនួយផ្នែកបច្ចេកទេសពីធនាគារអភិវឌ្ឍន៍អាស៊ីកំពុងព្រាងអនុក្រឹត្យមួយស្តីពីហេតុប៉ះពាល់សេដ្ឋកិច្ច-សង្គមដោយសារគម្រោងអភិវឌ្ឍន៍ ដែលគ្រប់គ្រងលើលទ្ធកម្មដោយបង្ខំលើដីធ្លី ក្នុងផលប្រយោជន៍សាធារណៈ ការតាំងទីលំនៅថ្មីរបស់សហគមន៍ដែលរងផលប៉ះពាល់ និងការវាយតម្លៃលើសិទ្ធិទទួលបានសំណង ។ ការិយាល័យបានចូលរួមក្នុងការពិគ្រោះយោបល់ និងបានដាក់ស្នើកង្វល់មួយចំនួនពាក់ព័ន្ធភាពស្របគ្នានៃសេចក្តីព្រាងអនុក្រឹត្យស្តីពីសិទ្ធិមានលំនៅដ្ឋានសមរម្យ ដូចបានទទួលស្គាល់ក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេ-ដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងរដ្ឋធម្មនុញ្ញ និងច្បាប់ភូមិបាលកម្ពុជា ។ ការិយាល័យបានចូលរួមក្នុងការពិភាក្សាជាមួយក្រុមសង្គមស៊ីវិលទាក់ទងនឹងសេចក្តីព្រាងអនុក្រឹត្យ ហើយបានគាំទ្រមតិរបស់សហគមន៍លើ កិច្ចដំណើរការព្រាងច្បាប់ ។

៤១. ពាក់ព័ន្ធនឹងបញ្ហាទាំងនេះ ការិយាល័យបានឃ្លាំមើលបរិយាកាសលើកស្ទួយនិងជំរុញដល់ការអនុវត្តន៍សិទ្ធិលើដីធ្លី និងការការពារធនធានធម្មជាតិ របស់អង្គការក្រៅរដ្ឋាភិបាល ក្រុមសង្គមស៊ីវិល និងបុគ្គលផ្សេងៗ ។ បុគ្គលិកសង្គមស៊ីវិលនានាធ្វើការនៅក្នុងចន្លោះមួយកាន់តែចង្អៀតទៅៗ និងក្នុងបរិយាកាសអរិភាព : អាជ្ញាធរតែងតែចោទប្រកាន់អង្គការក្រៅរដ្ឋាភិបាល ដែលកំពុងជួយសហគមន៍នានា ដើម្បីសំដែងអំពីកង្វល់របស់ខ្លួន ពីបទជាប់ទាក់ទិននឹងនយោបាយ និងការញុះញង់ ។ នៅក្នុងខេត្តមួយចំនួន ( រតនគីរី មណ្ឌលគីរី ក្រចេះ ស្ទឹងត្រែង ) បានចាប់ផ្តើមលេចចេញជារូបរាងឡើង នូវលំនាំនៃការរិតត្បិតសេរីភាពនៃការប្រជុំ និងការដើរហើរ របស់សហគមន៍មូលដ្ឋាននានា និងអង្គការក្រៅរដ្ឋាភិបាល ។

៤២. នៅក្នុងខេត្តមួយចំនួន ជាពិសេសក្នុងតំបន់ដែលមានជំលោះដីធ្លី និងធនធានធម្មជាតិ ដែលតែងតែកើតឡើង ច្រើននិងខ្លាំងក្លា ជារឿយៗអង្គការក្រៅរដ្ឋាភិបាលត្រូវគេតម្រូវឱ្យជូនដំណឹង ឬសុំការអនុញ្ញាតពីអាជ្ញាធរខេត្តជាមុន សិនមុននឹងទៅជួបអ្នកស្រុក កោះអញ្ជើញពួកគេឱ្យចូលរួមសិក្ខាសាលា ឬមុននឹងប្រជុំផ្សេងៗ ។ នៅក្នុងខែ ឧសភា ឆ្នាំ ២០០៧ នគរបាលខេត្តរតនគិរី បានបញ្ឈប់ការប្រជុំមួយ ដែលមានតំណាងមកពីអង្គការក្រៅរដ្ឋាភិបាល ថ្នាក់ជាតិនិង ខេត្តចូលរួមជាង៣០នាក់ ដោយនិយាយថាការប្រជុំនេះ ពុំមានការអនុញ្ញាតពីអាជ្ញាធរខេត្តឡើយ ។ នៅខេត្តរតនគិរី និងខេត្តមណ្ឌលគិរី ដែលមានជនជាតិដើមភាគតិចភាគច្រើន សមាជិកសហគមន៍តម្រូវឱ្យសុំការអនុញ្ញាតពីអាជ្ញាធរ ខេត្តជាមុនសិន មុននឹងទៅចូលរួមការប្រជុំនៅក្រៅខេត្ត ។ នៅក្នុងខេត្តរតនគិរី អង្គការក្រៅរដ្ឋាភិបាលមួយ កំពុង ធ្វើការជាមួយសហគមន៍ ដែលរងផលប៉ះពាល់ដោយទំនប់ទឹកខាងលើក្នុងប្រទេសវៀតណាម បានសុំការអនុញ្ញាត សំរាប់សមាជិកសហគមន៍ចំនួន១២នាក់ និងបុគ្គលិកពីរនាក់ឱ្យចូលរួមក្នុងសិក្ខាសាលាមួយ នៅភ្នំពេញក្នុងខែតុលា ឆ្នាំ២០០៧ : អភិបាលរងខេត្តបានបដិសេធការស្នើសុំ ហើយបានបញ្ជូនគរបាលខេត្តឱ្យបញ្ឈប់ដំណើររបស់ពួកគេនៅ តាមផ្លូវ ។ នៅក្នុងខេត្តរតនគិរីនេះដែរ អង្គការអាដហុក(ADHOC) ដែលបានចូលរួមយ៉ាងសកម្ម ក្នុងការការពារសិទ្ធិ ខាងដីធ្លី និងជនជាតិដើមភាគតិច ត្រូវបានគេហាមឃាត់នៅពាក់កណ្តាលខែធ្នូ មិនឱ្យបើកសិក្ខាសាលាមួយស្តីពីការ អនុវត្តន៍ច្បាប់ភូមិបាល ដែលនឹងមានការចូលរួមពីអាជ្ញាធរឃុំ និងស្រុក និងសហគមន៍មូលដ្ឋាន ។ ទោះជាយ៉ាងណា ក៏ដោយ សិក្ខាសាលាអាចធ្វើទៅបាន ហើយបន្ទាប់មកមានការដើរដង្ហែជាក្បួនតូចមួយដោយសន្តិវិធី តែត្រូវបាន បញ្ឈប់ និងបំបែកដោយប្រើរទុយោបាញ់ទឹករថយន្តពន្លត់អគ្គិភ័យ ។

៤៣. នៅក្នុងបរិបទនៃជម្លោះអំពីដីធ្លីដែលមិនទាន់ចុះបញ្ជី សកម្មជនសហគមន៍នៅតែបន្តទទួលរងការចោទប្រកាន់ ពីបទល្មើសព្រហ្មទណ្ឌក្រោមច្បាប់ភូមិបាល ដូចជាបទរំលោភលើទ្រព្យសម្បត្តិឯកជន ទោះបីកម្មសិទ្ធិភោគៈទៅលើដីធ្លី នោះ នៅមិនទាន់បានកំណត់ក្តី ។ ទោះជាយ៉ាងណាក៏ដោយ មានការចាត់វិធានការតិចតួចដើម្បីដោះស្រាយជម្លោះដីធ្លី ដែលមានមកជាយូរ ហើយដែលបានគំរាមកំហែងដល់ការចិញ្ចឹមជីវិតរបស់សហគមន៍ ហើយនិងការចោទប្រកាន់ពីបទ ព្រហ្មទណ្ឌ មិនបានធ្វើទៅលើភាគីដែលមានទំនាក់ទំនងល្អជាមួយអ្នកមានអំណាចនោះទេ ។ នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ ២០០៧ លោក ជា នី ត្រូវបានដោះលែងបន្ទាប់ពីបានជាប់ឃុំតាំងពីខែសីហា ឆ្នាំ២០០៦ ពាក់ព័ន្ធនិងជម្លោះដីធ្លីមិនទាន់- ចុះបញ្ជីជាមួយមន្ត្រីយោធា និងឈ្មួញអ្នកមាននៅស្រុកបវេល ខេត្តបាត់ដំបង ។ មានភាពមិនប្រក្រតីជាច្រើនក្នុង ចំណាត់ការនីតិវិធីរបស់តុលាការពាក់ព័ន្ធនឹងការចោទប្រកាន់លើគាត់ ដោយរួមទាំងសវនាការកំបាំងមុខ នៅក្នុងការ ចោទប្រកាន់លើកទីមួយ និងសាលក្រមសំរេចឱ្យមានទោសពីបទចោទប្រកាន់ពីរដែលបានកែប្រែ ក្នុងពេលឬក្រោយ ពេលសវនាកា ។ ក្នុងខែឧសភា និងមិថុនា ឆ្នាំ២០០៧ សមាជិកសហគមន៍បីរូបមកពីអូរវល្លិប្រេង ខេត្តបាត់ដំបង ត្រូវ បានឃុំខ្លួននិងចោទប្រកាន់ពីបទរំលោភលើទ្រព្យសម្បត្តិឯកជន ក្នុងរឿងជម្លោះដីធ្លីជាមួយឈ្មួញអ្នកមាន និងមាន

ទំនាក់ទំនងល្អជាមួយអ្នកមានអំណាច ។ ទោះបីជាចៅក្រមជំនុំជម្រះឧទ្ធរណ៍បានច្រានចោលការចោទប្រកាន់លើលោក ជឹម កែវ រងចាំសេចក្តីសំរេចលើវិវាទអំពីសិទ្ធិកម្មសិទ្ធិលើដីធ្លី គាត់នៅជាប់ឃុំឃាំងនៅឡើយ ដោយសារតែព្រះរាជអាជ្ញាបានប្តឹងឧទ្ធរណ៍នឹងសេចក្តីសំរេចនេះ ។ លោកទិត ប៊ុនឈឿន និងលោក ហុង ជា ត្រូវបានតុលាការសំរេចឱ្យនៅក្រៅឃុំ ប៉ុន្តែក៏ជាប់ឃុំឃាំងជាដដែល ក៏ព្រោះតែព្រះរាជអាជ្ញាបានប្តឹងឧទ្ធរណ៍នឹងសេចក្តីសំរេចនេះ ។ នៅទីបំផុត បុរសទាំងបីនាក់នេះត្រូវបានតុលាការដោះលែងឱ្យមានសេរីភាពវិញក្នុងខែកញ្ញា ឆ្នាំ២០០៧ បន្ទាប់ពីសមាជិកសហគមន៍ចំនួន៦៥ នាក់បានធ្វើដំណើរទៅទីក្រុងភ្នំពេញ ដើម្បីធ្វើការតវ៉ា និងអំពាវនាវសុំឱ្យក្រសួងយុត្តិធម៌ ចាត់វិធានការដើម្បីដោះលែងបុរសទាំងនោះឱ្យមានសេរីភាពឡើងវិញ ។

៤៤. បទព្រហ្មទណ្ឌក៏ត្រូវបានចោទប្រកាន់ផងដែរទៅលើសមាជិកសហគមន៍ ដែលបានធ្វើការតវ៉ាចំពោះការបណ្តេញចេញ ឬការប៉ុនប៉ងបណ្តេញពួកគេចេញពីដីធ្លីនិងលំនៅដ្ឋានរបស់ខ្លួន ។ បន្ទាប់ពីមានការបណ្តេញចេញដោយហឹង្សាទៅលើប្រជាពលរដ្ឋជាង ១០០ គ្រួសារនៅក្រុងព្រះសីហនុ ដោយមន្រ្តីនគរបាលប្រដាប់អាវុធក្នុងខែមេសា ឆ្នាំ២០០៧ ដែលក្នុងនោះមានអ្នកស្រុកជាច្រើននាក់ត្រូវបានគេវាយដំ អ្នកស្រុក ១៣ នាក់ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ពីបទអំពើបង្ករបួសស្នាមដោយចេតនា និងការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិដោយចេតនា ឬបទសមគំនិតក្នុងបទល្មើសអាជ្ញាទាំងនេះ ។ ទោះបីជាគ្មានភស្តុតាងជាក់ស្តែងក្តី ក៏មានមនុស្សប្រាំបីនាក់ត្រូវបានកាត់ឱ្យជាប់ទោស : ភាគច្រើននៃពួកគេបានបំរើទោស ក្នុងពេលជាប់ឃុំបណ្តោះអាសន្ន ហើយមានសិទ្ធិទទួលបាននូវការដោះលែង ប៉ុន្តែអ្នកទាំងនោះនៅតែជាប់ឃុំជាដដែល ដោយសារព្រះរាជអាជ្ញាបានប្តឹងឧទ្ធរណ៍នឹងសេចក្តីសំរេចនេះ ។ មិនមានវិធានការណាមួយត្រូវបានចាត់ទៅលើមន្រ្តីនគរបាលទាំងឡាយ ដែលបានប្រើកំលាំងហួសហេតុ បំផ្លិចបំផ្លាញលំនៅដ្ឋាន និងវាយធ្វើបាបអ្នកស្រុកឡើយ ។ សមាជិកសហគមន៍ប្រាំបួននាក់បានប្រឈមមុខនឹងការចោទប្រកាន់ពីបទព្រហ្មទណ្ឌ នៅសហគមន៍ ដីក្រហមនៅកណ្តាលទីក្រុងភ្នំពេញ ដែលមានប្រជាពលរដ្ឋជាង៣៥០ គ្រួសារប្រឈមមុខនឹងការបណ្តេញដែលកំពុងតែកើតមាន ដើម្បីទុកលទ្ធភាពឱ្យក្រុមហ៊ុនមួយអភិវឌ្ឍន៍តំបន់នោះ ។ ការចោទប្រកាន់ទាំងនេះ ទំនងជាគ្មានភស្តុតាងគ្រប់គ្រាន់ឡើយ ហើយបានធ្វើឡើងដើម្បីកាត់បន្ថយសកម្មភាពរបស់សមាជិកសហគមន៍ ដែលធ្វើការតវ៉ាចំពោះការបណ្តេញចេញនេះ ។

៤៥. ការិយាល័យបានឃ្លាំមើលយ៉ាងជិតស្និទ្ធនូវករណីមួយ ដែលមានជនជាតិដើមភាគតិច១២ នាក់មកពីខេត្តរតនគីរី បានចាត់វិធានការតាមផ្លូវច្បាប់ ដើម្បីលុបចោលកិច្ចសន្យាលក់ទិញដីមួយដោយមូលហេតុថាជាការក្លែងបន្លំរបស់ក្រុមហ៊ុនចំការកៅស៊ូកម្ពុជាមួយ ដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយមន្រ្តីរដ្ឋាភិបាលជាន់ខ្ពស់ ។ ក្រុមហ៊ុនបានដាក់បណ្តឹងព្រហ្មទណ្ឌមួយប្រឆាំងនឹងអ្នកស្រុក ដោយចោទប្រកាន់ពីបទក្លែងបន្លំលិខិតស្នាមនិងបរិហារកេរ្តិ៍ និងចោទប្រកាន់ថាមេធាវីរបស់ពួកគេនិងតំណាងអង្គការក្រៅរដ្ឋាភិបាលពីរនាក់ជាអ្នកញុះញង់និងសមគំនិតជាមួយអ្នកស្រុក ។

ក្រុមហ៊ុននេះក៏បានដាក់ពាក្យបណ្តឹងទៅគណៈមេធាវីផងដែរ ប្រឆាំងនឹងមេធាវីដប់នាក់ ដែលតំណាងឱ្យអ្នកស្រុក ដោយចោទប្រកាន់ថាពួកគេបានញុះញង់អ្នកស្រុកឱ្យដាក់ពាក្យបណ្តឹងប្រឆាំងនឹងខ្លួន ។ ពាក្យបណ្តឹងទាំងពីរនេះកំពុងស្ថិតក្នុងការស៊ើបអង្កេត ។

## ច. ការប្រកាន់ខ្ជាប់នូវសន្ធិសញ្ញានានា ស្តីពីសិទ្ធិមនុស្សអន្តរជាតិ

៤៦. កម្ពុជាមានប្រវត្តិល្អបំផុតខាងការផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្សនានានៅតំបន់អាស៊ី : កម្ពុជាបានផ្តល់សច្ចាប័នលើសន្ធិសញ្ញាសិទ្ធិមនុស្សសំខាន់ៗចំនួនប្រាំមួយ និងបានចុះហត្ថលេខាលើសន្ធិសញ្ញាពីរផ្សេងទៀត កម្ពុជាបានផ្តល់សច្ចាប័នលើពិធីសារបន្ថែមចំនួនបី និងចុះហត្ថលេខាលើពិធីសារបីផ្សេងទៀត ហើយបានផ្តល់សច្ចាប័នលើអនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិ(ILO) ចំនួនប្រាំពីរ ។ ទន្ទឹមនឹងការប្តេជ្ញាចិត្តជាផ្លូវការទាំងនេះ បង្ហាញអំពីការប្តេជ្ញាចិត្តមួយដ៏សំខាន់របស់រដ្ឋាភិបាលចំពោះបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ក៏ការអនុវត្តន៍កាតព្វកិច្ចខាងសន្ធិសញ្ញានៅមានកំរិតនៅឡើយ ។ កម្ពុជាក៏បានចូលជាសមាជិកអនុសញ្ញាប្រឆាំងអំពើពុករលួយ នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៧ ដែរ ។

៤៧. នៅក្នុងឆ្នាំ២០០៧ កម្ពុជាបានពង្រឹងយ៉ាងខ្លាំងក្លានូវការតាំងចិត្តជាផ្លូវការរបស់ខ្លួនចំពោះបទដ្ឋានសន្ធិសញ្ញាអន្តរជាតិ ដើម្បីការការពារ និងលើកស្ទួយសិទ្ធិមនុស្ស ។ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៧ កម្ពុជាបានកំកល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័នលើពិធីសារបន្ថែមលើអនុសញ្ញាប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ និងបន្ថោកបន្ទាប ។ ការិយាល័យបានបន្តការពិភាក្សាជាមួយសមភាគីរដ្ឋាភិបាលអំពីលទ្ធភាពក្នុងការផ្តល់ការជួយឧបត្ថម្ភផ្នែកបច្ចេកទេសពាក់ព័ន្ធនឹងការបង្កើតយន្តការបង្ការថ្នាក់ជាតិមួយ ដែលគួរតែបង្កើតបាននៅចុងខែមេសា ឆ្នាំ២០០៨ នេះ ។ បន្ទាប់ពីនោះ ក៏មានការផ្តល់សច្ចាប័ននៅថ្ងៃទី១ ខែសីហា ឆ្នាំ២០០៧ លើពិធីសារបន្ថែម ស្តីពីការបង្ការ ការបង្ក្រាប និងការផ្តន្ទាទោសការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ បន្ថែមទៅលើអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងឧក្រិដ្ឋកម្ម ដែលមានអង្គការចាត់តាំងឆ្លងដែន ។ ការិយាល័យបានផ្តល់យោបល់ដល់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាពាក់ព័ន្ធនឹងខ្លឹមសារនៃអនុសញ្ញាថ្មីស្តីពីសិទ្ធិជនពិការ ។ ជាលទ្ធផល ក្រសួងនេះបានស្នើទៅក្រសួងការបរទេស សុំឱ្យកម្ពុជាចុះហត្ថលេខា និងបន្ទាប់មកផ្តល់សច្ចាប័នលើអនុសញ្ញា និងពិធីសារបន្ថែមនៃអនុសញ្ញានេះ ។ បន្ទាប់ពីចុះហត្ថលេខាលើលិខិតុបករណ៍ពីរនៅថ្ងៃទី១ ខែតុលា ឆ្នាំ ២០០៧ ការិយាល័យ ជាមួយនិងអង្គការពលកម្មអន្តរជាតិ(ILO) និងមូលនីធិសហប្រជាជាតិ ដើម្បីកុមារ (UNICEF) ដោយសហការជាមួយក្រសួងសង្គមកិច្ច និងក្រុមប្រឹក្សាសកម្មភាពជនពិការ បានផ្តួចផ្តើមបង្កើតវេទិកាសាធារណៈ

មួយក្នុងគោលបំណងឱ្យតំណាងរាស្ត្រតស៊ូមតិ ដើម្បីឱ្យមានការផ្តល់សច្ចាប័នឱ្យបានឆាប់រហ័សលើអនុសញ្ញានេះ ស្របគ្នានឹងការអនុម័តច្បាប់ជាតិស្តីពីសិទ្ធិជនពិការ ។

៤៨. បច្ចុប្បន្ននេះ កម្ពុជាហួសពេលកំណត់ក្នុងការបញ្ជូនរបាយការណ៍ចំនួនដប់បួនទៅស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស ។ រដ្ឋាភិបាលក៏កំពុងតែដំណើរការរៀបចំរបាយការណ៍តាមកាលកំណត់លើកទីពីររបស់ខ្លួន ក្រោមអនុសញ្ញាស្តីពីសិទ្ធិកុមារ ដោយមានការជួយឧបត្ថម្ភពីមូលនិធិសហប្រជាជាតិដើម្បីកុមារ(UNICEF) ។ សេចក្តីព្រាងរបាយការណ៍តាមកាលកំណត់លើកក្រោយរបស់កម្ពុជា ក្រោមអនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ ដែលត្រូវបានដាក់ជូនទៅគណៈរដ្ឋមន្ត្រីក្នុងខែតុលា ឆ្នាំ២០០៦ មិនមានការរីកចំរើនទៅមុខទេ ។ ទោះបីជាកម្ពុជាបានក្លាយជាភាគីមួយនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ក្នុងខែសីហា ឆ្នាំ១៩៩២ ហើយក្តី កម្ពុជានៅមិនទាន់ដាក់ជូនរបាយការណ៍លើកទីមួយរបស់ខ្លួនក្រោមកតិកាសញ្ញានេះ ។

## ឆ. កិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិ

៤៩. ការិយាល័យបានបន្តផ្តល់យោបល់លើកិច្ចដំណើរការដែលកំពុងធ្វើ ដើម្បីបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិមួយ (NHRI) ស្របទៅនឹងគោលការណ៍ស្តីពីឋានៈនៃស្ថាប័នជាតិ (គោលការណ៍ទីក្រុងប៉ារីស) ។ បន្ទាប់ពីសន្និសិទថ្នាក់ជាតិនៅខេត្តសៀមរាបក្នុងខែកញ្ញា ឆ្នាំ២០០៦ ដែលក្នុងនោះលោកនាយករដ្ឋមន្ត្រីបានអនុម័តយល់ព្រមជាសាធារណៈលើគំនិតផ្តួចផ្តើមនេះ ក្រុមការងារថ្នាក់ជាតិមួយត្រូវបានបង្កើតឡើង ដែលមានតំណាងគណៈកម្មាធិការសិទ្ធិមនុស្សរដ្ឋាភិបាល និងអង្គការសិទ្ធិមនុស្សក្រៅរដ្ឋាភិបាលនានា ។ ការងាររៀបចំចងក្រងសេចក្តីព្រាងច្បាប់ដំបូង ដើម្បីបង្កើតស្ថាប័ននេះ ត្រូវបានប្រគល់ទៅឱ្យក្រុមការងារមួយនៃអង្គការក្រៅរដ្ឋាភិបាលនានា ដែលកំពុងប្រតិបត្តិការក្នុងវិស័យសិទ្ធិមនុស្ស និងជំនួយផ្នែកច្បាប់ ។ ស្ថាប័ននេះបានដាក់ជូនសេចក្តីព្រាងច្បាប់ដំបូងរបស់ខ្លួនទៅរដ្ឋាភិបាលក្នុងខែតុលា ឆ្នាំ២០០៧ ហើយបច្ចុប្បន្ននេះស្នើឱ្យមានពេលវេលាមួយវែងសំរាប់ការពិគ្រោះយោបល់ជាសាធារណៈលើសេចក្តីព្រាងច្បាប់នេះ ។

៥០. ការិយាល័យកំពុងស្វែងរកការធានាថា សេចក្តីព្រាងច្បាប់ណាមួយដើម្បីបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិមួយគួរតែផ្អែកទៅលើការព្រមព្រៀងជាទូទៅនៅក្នុងសង្គមកម្ពុជា ដោយមានការចូលរួមយ៉ាងពេញទំហឹងពីស្ថាប័ននានានៃរដ្ឋាភិបាល និងសង្គមស៊ីវិល ។ ដើម្បីជំរុញឱ្យមានការចូលរួមច្រើនថែមទៀត និងផ្តល់យោបល់ផ្នែកជំនាញក្នុងកិច្ចដំណើរការព្រាងច្បាប់ ការិយាល័យបានរៀបចំឱ្យមានបេសកកម្មជំនួយបច្ចេកទេសមួយក្នុងខែធ្នូ ឆ្នាំ ២០០៧ ដើម្បីជួប

ជាមួយរដ្ឋាភិបាល និងតំណាងសង្គមស៊ីវិល ពិនិត្យសេចក្តីព្រាងច្បាប់ដំបូង និងណែនាំពួកគេអំពីការងារ ត្រូវធ្វើជាបន្តទៀត ។ ការិយាល័យក៏បានជួយសម្រួលដល់ការចូលរួមផ្លូវការមួយរបស់ក្រុមរបស់គណៈប្រតិភូរដ្ឋាភិបាលកម្ពុជានៅក្នុងសិក្ខាសាលាមួយដែលមានរយៈពេលបីថ្ងៃ ស្តីពីការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិ ដែលបានរៀបចំឡើងដោយអង្គភាពស្ថាប័នជាតិនៃការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ដោយសហការជាមួយគណៈកម្មការសិទ្ធិមនុស្សនៃប្រទេសហ្វីលីពីន ។

## ជ. កិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលជាមួយក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេស

៥១. ក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍សហប្រជាជាតិ ២០០៦ — ២០១០ ដែលការិយាល័យបានរួមជាវិភាគទានជាដុំកំភួន គឺជាឯកសារមួយរឹងមាំដែលផ្អែកលើសិទ្ធិជាចម្បង ដែលកំណត់យកវិស័យបួនធំៗ : គឺអភិបាលកិច្ចល្អនិងការលើកស្ទួយ និងការពារសិទ្ធិមនុស្ស កសិកម្មនិងភាពក្រីក្រនៅជនបទ ការកសាងសមត្ថភាព និងការអភិវឌ្ឍន៍ធនធានមនុស្សសំរាប់វិស័យសង្គមកិច្ច និងគាំទ្រដល់ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ (២០០៦-២០១០) ។ ទន្ទឹមនឹងនេះកម្មវិធីរបស់ការិយាល័យរួមចំណែកក្នុងគោលដៅទាំងអស់នេះ ការិយាល័យសង្កត់ធ្ងន់តែទៅលើការការពារ ការជួយឧបត្ថម្ភ និងការងារប្រឹក្សាយោបល់នៅក្នុងវិស័យពីរដំបូង ។

៥២. ការិយាល័យបានចូលរួមយ៉ាងទៀងទាត់ នៅក្នុងការប្រជុំរបស់ក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេស ដោយរួមទាំងការប្រជុំប្រធានទីភ្នាក់ងារ និងគណៈកម្មាធិការប្រឹក្សាយោបល់ស្តីពីគោលដៅអភិវឌ្ឍន៍សហសវត្ស ដែលរួមទាំងការទទួលខុសត្រូវខាងសិទ្ធិមនុស្សផងដែរ ។ ការិយាល័យបានធ្វើការជាមួយទីភ្នាក់ងារដោយឡែកៗពីគ្នាលើបញ្ហាដែលជាកង្វល់រួម ឧទាហរណ៍ ជាមួយអង្គការពលកម្មអន្តរជាតិ (ILO) លើបញ្ហាពាក់ព័ន្ធនឹងជនជាតិដើមភាគតិច សេរីភាពក្នុងការប្រជុំ និងសេរីភាពការបង្កើតសមាគម និងជាមួយមូលនីធិអភិវឌ្ឍន៍សហប្រជាជាតិ ដើម្បីស្ត្រី (UNIFEM) ពាក់ព័ន្ធនឹងរបាយការក្រោមសន្និសញ្ញា និងការតាមដានជាមួយមូលនីធិសហប្រជាជាតិដើម្បីកុមារ (UNICEF) ទាក់ទិននឹងយុត្តិធម៌អនីតិជន និងសិទ្ធិជនពិការ ។ ការិយាល័យបានសហការជាមួយកម្មវិធីអង្គការសហ-ប្រជាជាតិសំរាប់លំនៅដ្ឋានមនុស្សជាតិ និងទីក្រុង (UN-HABITAT) ក្នុងការព្រាងឯកសារស្តីពីទស្សនៈរបស់ក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេស ស្តីពីការបណ្តេញចេញនិងការតាំងលំនៅដ្ឋានដោយគ្មានការស្ម័គ្រចិត្ត ។

៥៣. ក្រៅពីប្រព័ន្ធសហប្រជាជាតិ ការិយាល័យបានបន្តធ្វើការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍ពហុភាគីនិងទ្វេរភាគី ដើម្បីជួយធ្វើសមារណកម្មនិងអនុវត្តបទដ្ឋានសិទ្ធិមនុស្សទៅក្នុងគោលនយោបាយ និងកម្មវិធី

អភិវឌ្ឍន៍នានា ។ ការិយាល័យបានចូលរួមវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (ដែលពីមុនហៅ ថាក្រុមពិគ្រោះយោបល់) ហើយនៅតែសកម្មក្នុងក្រុមការងារបច្ចេកទេសស្តីពីកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ និងដីធ្លី ក្រុមពីរក្នុងចំណោមក្រុមទាំងដប់ប្រាំបួន ដែលបានបង្កើតឡើងដោយរដ្ឋាភិបាលនិងប្រទេសអ្នកផ្តល់ជំនួយ ដើម្បីរៀបចំយុទ្ធសាស្ត្ររួម និងផែនការសកម្មភាព និងឃ្លាំមើលការរីកចំរើនលើសន្ទស្សន៍ទាំងឡាយដែលបានព្រមព្រៀង ។

## ឈ. កម្មវិធីអប់រំ បណ្តុះបណ្តាល និងព័ត៌មានសាធារណៈ

៥៤. បន្តអនុវត្តកម្មវិធីរបស់ខ្លួន ដើម្បីបោះពុម្ពផ្សាយអត្ថបទថ្មីដែលបានបកប្រែជាភាសាខ្មែរនៃសន្ធិសញ្ញាសិទ្ធិមនុស្សសំខាន់ៗនានា ការិយាល័យបានបញ្ចប់ការបកប្រែជាភាសាខ្មែរនូវអនុសញ្ញាស្តីពីសិទ្ធិជនពិការ ដោយសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រុមប្រឹក្សាសកម្មភាពជនពិការ ។ ការបកប្រែនេះ គឺផ្អែកលើអត្ថបទដំបូងដែលបានរៀបចំឡើងដោយជនពិការនៅអង្គការ Jesuit Refugee Service នៅទីក្រុងភ្នំពេញ ។ លុះក្រោយមក អនុសញ្ញានេះត្រូវបានបោះពុម្ពផ្សាយជាពីរភាសាគឺភាសាអង់គ្លេស និងភាសាខ្មែរ ដោយសហការគ្នាជាមួយអង្គការពលកម្មអន្តរជាតិ(ILO) និងមូលនិធិសហប្រជាជាតិ ដើម្បីកុមារ (UNICEF) ។

៥៥. ក្នុងការឆ្លើយតបទៅនឹងការផ្តល់សច្ចាប័នលើពិធីសារបន្ថែម លើអនុសញ្ញាប្រឆាំងទារុណកម្មនិងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ការិយាល័យបានបោះពុម្ពផ្សាយអនុសញ្ញានេះ និងពិធីសារបន្ថែមនៃអនុសញ្ញានេះក្នុងអត្ថបទតែមួយ ដែលមានពីរភាសាគឺអង់គ្លេសនិងភាសាខ្មែរ ហើយអនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ ដែលត្រូវបោះពុម្ពផ្សាយក្នុងទម្រង់ដូចគ្នានេះ ។ ក្នុងទម្រង់ជាកូនសៀវភៅដែលអាចដាក់ក្នុងហោប៉ៅបានជាពីរភាសា ការិយាល័យក៏បានបោះពុម្ពលិខិតុបករណ៍អង្គការសហប្រជាជាតិសំខាន់ៗស្តីពីចៅក្រម ព្រះរាជអាជ្ញា និងមេធាវី ហើយបានធ្វើការចែកចាយជាទូលំទូលាយដល់សមាជិកខាងវិជ្ជាជីវៈច្បាប់ និងបានបោះពុម្ពសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច ។

៥៦. ដោយគ្រោងជាមុននៃការប្រារព្ធពិធីពេញមួយឆ្នាំឈានទៅអបអរសាទរខួបលើកទីហុកសិបនៃការអនុម័តសេចក្តីប្រកាសជាសកល ស្តីពីសិទ្ធិមនុស្ស ដែលស្របពេលគ្នានឹងខួបលើកទីដប់ប្រាំនៃការប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញកម្ពុជា ការិយាល័យក៏បានរៀបចំកម្រងឯកសារជាភាសាខ្មែរ នូវឯកសារធម្មនុញ្ញកម្ពុជា ក្នុងគោលបំណងការពារសិទ្ធិមនុស្ស ដោយរួមទាំងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានា ដែលកម្ពុជាគឺជាភាគី ។

៥៧.  ពាក់ព័ន្ធនឹងការអនុម័តច្បាប់សំខាន់ៗមួយចំនួននៅពេលថ្មីៗនេះ ដោយរួមទាំងក្រមនីតិវិធីពីរផងនោះ ការិយាល័យកំពុងស្ថិតក្នុងដំណាក់កាលចុងក្រោយនៃការរៀបចំកម្រងឯកសារបន្ថែមលើកម្រងឯកសារច្បាប់ជាភាសាខ្មែរ បោះពុម្ពលើកទីបួន ដែលបានចែកចាយរួចហើយក្នុងខែកញ្ញា ឆ្នាំ២០០៥ កន្លងមកនេះ ។ ការចែកចាយកម្រងឯកសារច្បាប់បោះពុម្ពលើកទីបួនត្រូវបានបញ្ចប់ហើយៗ បច្ចុប្បន្ននេះកម្រងឯកសារនេះនៅមានតិចតួចក្នុងស្តុក ។ ទោះជាយ៉ាងណាក៏ដោយ កម្រងឯកសារច្បាប់នេះមាននៅលើវិបសាយរបស់ការិយាល័យ ហើយរួមទាំងច្បាប់ដែលទើបនឹងអនុម័តថ្មីៗផងដែរ ។ ការិយាល័យក៏បានសហការជាមួយនិស្សិតច្បាប់មួយក្រុមពីសាកលវិទ្យាភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដើម្បីផលិតចេញជាកម្រងឯកសារច្បាប់ក្នុងរូបភាពជាស៊ីឌីរ៉ូម(CD-ROM) ដែលមានអត្ថបទច្បាប់ទាំងស្រុងដែលងាយស្វែងរក ។ គំរោងនេះ ដែលជាគំនិតផ្តួចផ្តើមរបស់និស្សិតផ្ទាល់ បង្ហាញអំពីតម្លៃដែលបានដាក់លើកម្រងឯកសារនេះ សំរាប់ជាមរតកដល់ប្រជាពលរដ្ឋកម្ពុជាជំនាន់ក្រោយទទួលយកបច្ចេកវិជ្ជាថ្មីផ្នែកឌីជីថល ។

៥៨.  ការិយាល័យបានធ្វើការរៀបចំវិបសាយរបស់ខ្លួនឡើងវិញ ដើម្បីឱ្យស្របគ្នានឹងការបង្កើតនៅលើវិបសាយរបស់ការិយាល័យធំនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស(OHCHR) ។ វិបសាយថ្មីនឹងបញ្ចូលអត្ថបទជាភាសាខ្មែរ និងផ្តល់ព័ត៌មានបន្ថែមអំពីសកម្មភាពការងាររបស់ការិយាល័យប្រចាំនៅកម្ពុជា ក៏ដូចជាឯកសារជាភាសាអង់គ្លេសនិងខ្មែរទាក់ទិនការងាររបស់ ការិយាល័យOHCHR តំណាងពិសេសអ្នករាយការណ៍ពិសេស និងស្ថាប័នសន្ធិសញ្ញានានា និងសេចក្តីសំរេចចិត្តផ្សេងៗពាក់ព័ន្ធនឹងកម្ពុជា ។

## II. ការជួយឧបត្ថម្ភដល់តំណាងពិសេសរបស់លោកអគ្គលេខាធិការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា

៥៩.  ការិយាល័យOHCHR ប្រចាំនៅកម្ពុជាមានអាណត្តិគាំទ្រដល់តំណាងពិសេសនៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា លោក យ៉ាស្ហ ហ្គាយ ក្នុងការបំពេញអាណត្តិការងាររបស់លោកដើម្បីជួយដល់រដ្ឋាភិបាលនិងប្រជាជនកម្ពុជា ក្នុងការលើកស្ទួយនិងការការពារសិទ្ធិមនុស្ស ។ ការិយាល័យបានជួយសំរួលដល់បេសកកម្មលើកទីបី និងលើកទីបួនមកកាន់កម្ពុជារបស់លោកតំណាងពិសេសក្នុងខែឧសភា និងខែធ្នូ ឆ្នាំ២០០៧ ។ ក្នុងខែឧសភា ឆ្នាំ២០០៧ លោកតំណាងពិសេសបានមានឱកាសជួបជាមួយលោក ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងប្រធានគណៈកម្មការជាតិរៀបចំការបោះឆ្នោត ។ ក្នុងខែធ្នូ លោកបានផ្តោតការយកចិត្តទុកដាក់លើសិទ្ធិទទួលបានយុត្តិធម៌ និងសិទ្ធិលើដីធ្លីហើយបានធ្វើទស្សនកិច្ចទៅកាន់ខេត្តរតនគីរី ។ នៅទីក្រុងភ្នំពេញ លោក ហ្គាយ បានធ្វើការពិភាក្សាជាមួយប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាមន្ត្រីជាន់ខ្ពស់

តុលាការនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ លោកក៏បានទៅទស្សនកិច្ចនៅតំបន់ដែលប្រជាពលរដ្ឋត្រូវគេបណ្តេញចេញ ហើយបានចូលរួមក្នុងពិធីអបអរសាទរទិវាសិទ្ធិមនុស្សអន្តរជាតិនៅកណ្តាលទីក្រុងភ្នំពេញ ។ គួរឱ្យសោកស្តាយណាស់ ដោយសារមិនមានមន្ត្រីរដ្ឋាភិបាលអាចជួបជាមួយលោកតំណាងពិសេស ក្នុងដំណើរបេសកកម្មលើកទីបួននេះ ទោះបីជាមានការជូនដំណឹងជាមុន អំពីបេសកកម្មរបស់លោកហើយក្តី ។ នៅក្នុងដំណើរទស្សនកិច្ចទាំងពីរនេះ កម្មវិធីរបស់លោក ហ្គាយ រួមមានការពិភាក្សាជាមួយតំណាងនានានៃអង្គការក្រៅរដ្ឋាភិបាល សហជីពកម្មករ គណបក្សនយោបាយ និងអង្គទូតនានា ព្រមទាំងក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេសផងដែរ ។

## III. កិច្ចការបុគ្គលិក និងរដ្ឋបាលរបស់ការិយាល័យ ឧត្តមស្នងការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា

៦០. OHCHR នៅតែជាការិយាល័យមួយប្រចាំប្រទេសនៅទីក្រុងភ្នំពេញ ហើយមានការិយាល័យមួយប្រចាំតំបន់ដែលស្ថិតនៅក្នុងខេត្តបាត់ដំបង ។ ការិយាល័យនេះមានបុគ្គលិកអន្តរជាតិប្រាំបីនាក់ និងបុគ្គលិកក្នុងស្រុក២០នាក់ ហើយមានបុគ្គលិកអន្តរជាតិមួយរូបដែលផ្តល់ដោយអង្គការអ្នកស្ម័គ្រសហប្រជាជាតិ(UNV) ។ បុគ្គលិកបួននាក់បំរើការនៅការិយាល័យប្រចាំតំបន់ក្នុងខេត្តបាត់ដំបង ។ OHCHR ក៏មានការិយាល័យតូចមួយប្រចាំនៅតុលាការក្រុងភ្នំពេញផងដែរ ។ រចនាសម្ព័ន្ធរបស់ការិយាល័យប្រចាំប្រទេសកម្ពុជារួមមាន : តំណាង និងតំណាងរងការិយាល័យ កម្មវិធីចំនួនបី និងផ្នែករដ្ឋបាលមួយ ។

៦១. តំណាងការិយាល័យទទួលខុសត្រូវលើគោលនយោបាយ និងការគ្រប់គ្រងទូទៅ ។ ភារកិច្ចនេះរួមមានការបង្កើតឡើងវិញនិងការពង្រឹងកិច្ចពិភាក្សា និងកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាលនិងសង្គមស៊ីវិលលើវិស័យទាំងឡាយដែលជាកង្វល់ខាងសិទ្ធិមនុស្ស សម្របសម្រួលនិងជួយឧបត្ថម្ភដល់លោកតំណាងពិសេស ចូលរួមក្នុងប្រព័ន្ធសហប្រជាជាតិ និងសម្រួលដល់ទំនាក់ទំនងខាងក្រៅ និងជាមួយប្រទេសអ្នកផ្តល់ជំនួយ ។ តំណាងរងការិយាល័យមានភារកិច្ចធានាសម្របសម្រួលកិច្ចការប្រចាំថ្ងៃ និងគ្រប់គ្រងកម្មវិធីរបស់ការិយាល័យ ក៏ដូចជាទំនាក់ទំនងរវាងការអនុវត្តន៏កម្មវិធី និងការគាំទ្រផ្នែករដ្ឋបាល ។ មុខងាររបស់ផ្នែកកម្មវិធី ត្រូវបានបរិយាយជាលំអិតនៅក្នុងកថាខ័ណ្ឌទី៤ និងទី៥ និងផ្នែកបន្ទាប់មកទៀតនៃរបាយការណ៍នេះ ។ ផ្នែករដ្ឋបាលមានភារកិច្ចផ្តល់ការគាំទ្រផ្នែកបុគ្គលិករដ្ឋបាលនិងហិរញ្ញវត្ថុ ភស្តុភានិងសេវាផ្សេងៗ ដូចជាភារកិច្ចស្នូលផ្នែកសន្តិសុខ ។

៦២. នៅក្នុងខែធ្នូ ឆ្នាំ២០០៧ ការិយាល័យបានចាត់តាំងឱ្យមានការពិនិត្យពីខាងក្រៅលើកម្មវិធីរបស់ខ្លួន ដើម្បីធ្វើការវាយតម្លៃអំពីលទ្ធភាពដែលអាចបញ្ចូលទស្សនវិស័យខាងយ៉េនឌ័រទៅក្នុងការងាររបស់ខ្លួនដោយរបៀបណា ។

៦៣. ថវិកាទៀងទាត់របស់អង្គការសហប្រជាជាតិសំរាប់ចំណាយលើប្រតិបត្តិការរបស់ការិយាល័យ (OHCHR) នៅកម្ពុជា រួមទាំងប្រាក់បៀវត្សរបស់បុគ្គលិកអន្តរជាតិប្រាំពីរនាក់ និងបុគ្គលិកក្នុងស្រុក២០ នាក់ផងដែរ ។ វិភាគទានស្ម័គ្រចូលក្នុងមូលនិធិទំនុកចិត្តសហប្រជាជាតិសំរាប់កម្មវិធីអប់រំអំពីសិទ្ធិមនុស្សនៅកម្ពុជា គ្របដណ្តប់ទៅលើការចំណាយទាំងអស់ផ្សេងទៀត រួមទាំងសកម្មភាពកម្មវិធីសំខាន់ៗនិងប្រាក់បៀវត្សបុគ្គលិកដែលមិនស្ថិតក្នុងខ្ទង់ថវិកាទៀងទាត់ ។ មូលនិធិទំនុកចិត្តត្រូវបានគ្រប់គ្រងដោយការិយាល័យអង្គការសហប្រជាជាតិប្រចាំនៅទីក្រុងហ្សឺណែវ ។

**ចប់**